

# គោលការណ៍ណែនាំអាស៊ានស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ

one vision
one identity
one community

# គោលការណ៍ណែនាំអាស៊ានស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ

មាតិកា


គោលការណ៍ណែនាំអាស៊ានស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ........................................... 1

អក្សរកាត់ ........................................................................................................................... 2

I. សេចក្តីផ្តើម ........................................................................................................................ 3

II. គោលបំណងនៃគោលការណ៍ណែនាំ................................................................................................. 5

III. អ្នកគ្រោងប្រើប្រាស់ និងភាគីពាក់ព័ន្ធគោលដៅ................................................................................. 6

IV. ប្រភព និងឯកសារយោងនៃគោលការណ៍ណែនាំ ..................................................................................... 6

V. គោលការណ៍ណែនាំទូទៅ ........................................................................................................... 8

V.1. ការផ្តែកលើមូលដ្ឋាននៃសិទ្ធិ និងស្របតាមបទដ្ឋានអាស៊ាន និងអន្តជាតិ....................................................... 8

V.2. ការមិនរើសអើង និង ប្រព្រឹត្តកម្មដោយស្មើភាព............................................................................. 8

V.3. ការគិតគូរពីយេនឌ័រ និងការឆ្លើយតបចំពោះយេនឌ័រ ..................................................................... 9

V.4. បរិយាបន្ន និង ជំនួយចំគោលដៅសម្រាប់ពលករទេសន្តរប្រវេសន៍នេសាទ រួមទាំងពលករទេសន្តរប្រវេសន៍ដែលមិនមានឯកសារ និងពលករទេសន្តរប្រវេសន៍ដែលមានវិបត្តិ.................................................................................... 9

V.5. តម្លាភាព សុចរិតភាព និងគណនេយ្យភាព ............................................................................... 10

V.6. ការចូលរួម ការតំណាង ការបញ្ចេញមតិ និងទីភ្នាក់ងាររបស់ពលករទេសន្តរប្រវេសន៍នេសាទ ................................. 10

V.7. វិធីសាស្ត្ររដ្ឋាភិបាល និងសង្គមទាំងមូល .................................................................................... 10

V.8. គោលការណ៍ទំនួលខុសត្រូវរួមរវាងប្រទេសបញ្ជូន និងប្រទេសទទួល ..................................................... 11

V.9. គោលនយោបាយ និងកម្មវិធីផ្អែកលើមូលដ្ឋានភស្តុតាង ..................................................................... 11

V.10. ភាពជាដៃគូ និងកិច្ចសហការ.................................................................................................... 11

VI. គោលការណ៍ណែនាំអាស៊ានស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ ................................ 11

VI.1. ក្របខ័ណ្ឌគតិយុត្តិ.................................................................................................................. 11

VI.2. ការជ្រើសរើស និងការរកការងារឱ្យធ្វើដោយស្មើភាព និងក្រមសីលធម៌ ............................................... 15

VI.3. សិទ្ធិការងារ........................................................................................................................ 16

VI.4. សិទ្ធិទទួលបានការប្រាស្រ័យទាក់ទង និងព័ត៌មាន ......................................................................... 18

VI.5. ការអភិវឌ្ឍជំនាញ ការផ្តល់វិញ្ញាបនបត្រ និងការទទួលស្គាល់......................................................... 18

VI.6. អំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ច ......................................................................... 19

VI.7. ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម ........................................................................ 19

VI.8. ការទទួលបានយុត្តិធម៌ និងដំណោះស្រាយ.................................................................................. 20

VI.9. ការឆ្លើយតប និងការគាំទ្រក្នុងស្ថានភាពមានវិបត្តិ ........................................................................ 21

VI.10. កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូក្នុងតំបន់ ........................................................................... 21

VII. ការកសាងសមត្ថភាពរបស់ស្ថាប័ន និងដៃគូអនុវត្ត............................................................................ 21

VIII. ការកៀរគរធនធានសម្រាប់ការអនុវត្តគោលការណ៍ណែនាំ.................................................................... 21

IX. ការប្រើប្រាស់គោលការណ៍ណែនាំ................................................................................................ 22

X. ការត្រួតពិនិត្យ និងការវាយតម្លៃគោលការណ៍ណែនាំ ........................................................................ 22

ឧបសម្ព័ន្ធ៖ សទ្ទានុក្រមពាក្យគន្លឹះជាមួយនិយមន័យ.............................................................................. ២3

អក្សរកាត់

| | |
|---|---|
| ACMW | គណៈកម្មការអាស៊ានលើការអនុវត្តសេចក្ដីថ្លែងការណ៍អាស៊ាន ស្ដីពីការការពារ និងការលើកកម្ពស់ពលករទេសន្តរប្រវេសន៍ |
| ACTIP | អនុសញ្ញាអាស៊ានស្ដីពីការប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ |
| ACWC | គណៈកម្មការអាស៊ានស្ដីពីការលើកកម្ពស់ និងការការពារសិទ្ធិស្ត្រី និងកុមារ |
| AFML | វេទិកាអាស៊ានស្ដីពីទេសន្តរប្រវេសន៍ការងារ |
| AICHR | គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្ដីពីសិទ្ធិមនុស្ស |
| ALIC | សន្និសីទអធិការកិច្ចការងារអាស៊ាន |
| ALICOM | គណៈកម្មាធិការអធិការកិច្ចការងារអាស៊ាន |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| ASEAN Consensus | ឯកច្ឆន្ទភាពអាស៊ានស្ដីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ឆ្នាំ២០១៧ |
| SEAFDEC | មជ្ឈមណ្ឌលអភិវឌ្ឍន៍ជលផលអាស៊ីអាគ្នេយ៍ |
| Cebu Declaration | សេចក្ដីថ្លែងការណ៍អាស៊ានស្ដីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ឆ្នាំ២០០៧ |
| CEDAW | អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី |
| GCM | កតិកាសញ្ញាសកលស្ដីពីការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ |
| ICRMW | អនុសញ្ញាអន្តរជាតិស្ដីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ |
| ILO | អង្គការអន្តរជាតិខាងការងារ |
| OSH | សុវត្ថិភាព និងសុខភាពការងារ |
| RFMO | អង្គការគ្រប់គ្រងជលផលក្នុងតំបន់ |
| SDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SLOM | កិច្ចប្រជុំឧត្តមមន្ត្រីការងារអាស៊ាន |
| UN | អង្គការសហប្រជាជាតិ |

## I. សេចក្តីផ្តើម

1. មួយផ្នែកធំនៃពលករនេសាទលើពិភពលោកមកពីតំបន់នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)។ បណ្តារដ្ឋសមាជិកអាស៊ាន (AMS) គឺជាប្រទេសបញ្ជូន និងប្រទេសទទួលពលករទេសន្តរប្រវេសន៍ក្នុងវិស័យនេសាទ។ ប្រទេសកម្ពុជា មីយ៉ាន់ម៉ា ឥណ្ឌូណេស៊ី ហ្វីលីពីន ថៃ និងវៀតណាម គឺជាប្រទេសដ៏សំខាន់ដែលបញ្ជូនពលករទេសន្តរប្រវេសន៍ក្នុងវិស័យទាំងនេះ រួមទាំងពលករទេសន្តរប្រវេសន៍នេសាទដែលកំពុងធ្វើការនៅលើនាវាដែលដាក់ទង់ជាតិនៃប្រទេសផ្សេងដែលមិនមែនជាទង់ជាតិនៃប្រទេសរបស់ពួកគេ។ នៅក្នុងបរិបទនៃការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងតំបន់ ពលករទេសន្តរប្រវេសន៍នេសាទបានបំពេញការងារមួយផ្នែកធំនៅក្នុងវិស័យនេសាទ ដែលប្រទេសជាច្រើនបានចាត់ទុកពួកគាត់ជាពលករដ៏ចាំបាច់ ដោយសារតួនាទីដ៏សំខាន់របស់ពួកគេក្នុងការទ្រទ្រង់ជីវភាពរស់នៅ និងសន្តិសុខស្បៀងអាហារ។

2. ការងារសមរម្យ និងការងារប្រកបដោយផលិតភាពក្នុងវិស័យនេសាទ គឺជាមូលដ្ឋានគ្រឹះក្នុងការធានាឱ្យបាននូវប្រតិបត្តិការនេសាទប្រកបដោយប្រសិទ្ធភាព។ ពលករទេសន្តរប្រវេសន៍នេសាទមានសិទ្ធិទទួលបានលក្ខខណ្ឌការងារសមរម្យ។ ជាពិសេសពលករទេសន្តរប្រវេសន៍នេសាទជារឿយៗស៊ូទ្រាំនឹងហានិភ័យនៃពលកម្មដោយបង្ខំ និងឱនភាពនៃការងារសមរម្យធ្ងន់ធ្ងរដូចជា៖ គ្រោះថ្នាក់ ជំងឺ ការរំលោភបំពាន និងការអនុវត្តការជ្រើសរើស និងការដាក់ឱ្យធ្វើការដោយក្លែងបន្លំ ការដាក់នៅដាច់ដោយឡែក និងការរំលោភបំពានលើជនដែលងាយរងគ្រោះ និងត្រូវបានបោះបង់ចោល គ្មានកិច្ចព្រមព្រៀងការងារជាលាយលក្ខណ៍អក្សររបស់ពលករនេសាទ ការផ្តល់ប្រាក់ឈ្នួលទាប និងការកាត់ទុកប្រាក់ឈ្នួល ការរក្សាទុកឯកសារអត្តសញ្ញាណ ការចុះបញ្ជីខ្មៅនៅពេលប្រើប្រាស់សិទ្ធិ អំពើហិង្សា និងការបំភិតបំភ័យ ការផ្ទេរពលករនេសាទនៅសមុទ្រដោយខុសច្បាប់ រយៈពេលធ្វើការយូរហួសកម្រិត និងការរំលោភបំពានលើលក្ខខណ្ឌការងារ និងការរស់នៅ។ បណ្តារដ្ឋសមាជិកអាស៊ាន ប្តេជ្ញាប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ និងការពារពលករទេសន្តរប្រវេសន៍នេសាទដែលមិនទាន់គ្រប់អាយុ ឬអាចទទួលរងហានិភ័យស្រដៀងគ្នា។

3. ឆ្លើយតបទៅនឹងបញ្ហាដ៏ច្រើនទាំងនេះ សេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទត្រូវបានអនុម័តដោយរដ្ឋសមាជិកអាស៊ាន ក្នុងខែឧសភា ឆ្នាំ២០២៣ ក្នុងកិច្ចប្រជុំកំពូលលើកទី៤២។[1] សេចក្តីថ្លែងការណ៍នេះត្រូវបានបង្កើតឡើងដោយកិច្ចប្រជុំឧត្តមមន្ត្រីការងារអាស៊ាន (SLOM) និងគណៈកម្មការអាស៊ានលើការអនុវត្តសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ (ACMW) ដោយមានការពិគ្រោះជាមួយស្ថាប័នអាស៊ានទទួលបន្ទុកតាមវិស័យពាក់ព័ន្ធ និងភាគីពាក់ព័ន្ធ។ សេចក្តីថ្លែងការណ៍ត្រូវបានបង្កើតឡើងក្នុងគោលបំណងចូលរួមចំណែកក្នុងការការពារ និងការលើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ ជាពិសេសនៅលើនាវានេសាទ ដោយការលើកកម្ពស់ការយល់ដឹងរួមអំពីហានិភ័យនៃបញ្ហាដែលពលករទេសន្តរប្រវេសន៍នេសាទអាចប្រឈមមុខដែលត្រូវការការការពារកាន់តែប្រសើរឡើងសម្រាប់ពលករទេសន្តរប្រវេសន៍ ការប្តេជ្ញាចិត្តនិងការផ្តល់ការគាំទ្រពីតំបន់អាស៊ានលើការងារជាអាទិភាព។ តាមរយៈការអនុម័តសេចក្តីថ្លែងការណ៍នេះ រដ្ឋសមាជិកអាស៊ានបានប្តេជ្ញាលើកកម្ពស់សុខុមាលភាព និងការការពារពលករទេសន្តរប្រវេសន៍នេសាទតាមរយៈ៖
   - ក) **ការបញ្ជ្រាបការការពារពលករទេសន្តរប្រវេសន៍នេសាទ** នៅក្នុងគោលនយោបាយ យន្តការ និងដំណើរការពាក់ព័ន្ធទាំងអស់ស្តីពីការធ្វើទេសន្តរប្រវេសន៍
   - ខ) ការពង្រឹងវិធានការដើម្បី**ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និងធានាបាននូវការការពារសិទ្ធិការងារ**
   - គ) ចាត់វិធានការដើម្បី**កំណត់អត្តសញ្ញាណ ដោះស្រាយ និងដាក់ទណ្ឌកម្មគ្រប់ទម្រង់នៃអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើ**ពលករទេសន្តរប្រវេសន៍នេសាទ។
   - ឃ) ការ**ធ្វើឱ្យប្រសើរឡើងនូវការជ្រើសរើស និងការដាក់ឱ្យធ្វើការដោយយុត្តិធម៌** និងក្រមសីលធម៌ មុនសម្រេចចិត្តទៅរកការងារ មុនចេញដំណើរ និងការណែនាំក្រោយពេលមកដល់ និងការទទួលបានកិច្ចសន្យាការងារ។
   - ង) ការធ្វើឱ្យប្រសើរឡើងនូវ**លទ្ធភាពទទួលបានការប្រាស្រ័យទាក់ទង និងព័ត៌មាន**សម្រាប់ពលករទេសន្តរប្រវេសន៍នេសាទ និងក្រុមគ្រួសាររបស់ពួកគេ
   - ច) ការលើកទឹកចិត្តរដ្ឋសមាជិកអាស៊ានឱ្យបង្កើតគំនិតផ្តួចផ្តើម ឬបញ្ចប់**កិច្ចព្រមព្រៀងទ្វេភាគី** ជាពិសេសក្នុងដំណើរការជ្រើសរើស និងការដាក់ឱ្យធ្វើការ ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មប្រកបដោយសុវត្ថិភាព និងការទទួលបានយុត្តិធម៌ និងដំណោះស្រាយ
   - ឆ) ស្វែងរកកិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋសមាជិកអាស៊ាន លើ**ការប្រមូល និងចែករំលែកទិន្នន័យ**

[1] សម្រាប់គោលបំណងនៃសេចក្តីថ្លែងការណ៍ "ពលករទេសន្តរប្រវេសន៍នេសាទ" សំដៅលើពលករទេសន្តរប្រវេសន៍ដែលធ្វើការក្នុងគ្រប់សមត្ថភាព ឬប្រកបមុខរបរលើនាវានេសាទពាណិជ្ជកម្ម ដែលប្រើទង់ជាតិប្រទេសផ្សេងក្រៅពីទង់ជាតិនៃប្រទេសរបស់ខ្លួន។

ជ) ការលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូសម្រាប់**ការអនុវត្តច្បាប់ឱ្យកាន់តែមានប្រសិទ្ធភាព** និងក្នុងកិច្ចការពារពលករទេសន្តរប្រវេសន៍នេសាទនៅក្នុងតំបន់អាស៊ានក្នុងដំណើរការធ្វើទេសន្តរប្រវេសន៍ទាំងមូល។

ឈ) **ការកៀរគរធនធាន**សម្រាប់ការអនុវត្តសេចក្តីថ្លែងការណ៍។

4. លិខិតុបករណ៍ស្តីពីការធ្វើទេសន្តរប្រវេសន៍អាស៊ានបានបញ្ចូលការប្តេជ្ញាចិត្តរបស់រដ្ឋសមាជិកអាស៊ានដើម្បីលើកកម្ពស់សក្តានុពល និងសេចក្តីថ្លៃថ្នូរពេញលេញរបស់ពលករទេសន្តរប្រវេសន៍ រួមទាំងពលករទេសន្តរប្រវេសន៍នេសាទផងដែរ។

5. មាត្រា ៨ នៃសេចក្តីប្រកាសរបស់អាស៊ានស្តីពីការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ (ហៅកាត់ថា "សេចក្តីថ្លែងការណ៍សេប៊ូ") តម្រូវឱ្យរដ្ឋសមាជិកអាស៊ានមានតួនាទី៖ "លើកកម្ពស់ការការពារការងារដោយយុត្តិធម៌ និងសមរម្យ ការទូទាត់ប្រាក់ឈ្នួល និងលទ្ធភាពទទួលបានលក្ខខណ្ឌការងារ និងជីវភាពរស់នៅដ៏សមរម្យរបស់ពលករទេសន្តរប្រវេសន៍"។

6. មាត្រា១០ នៃឯកច្ឆន្ទភាពអាស៊ានស្តីពីការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ (ហៅកាត់ថា "ឯកច្ឆន្ទភាពអាស៊ាន") ចែងថា៖ "ក្រោមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយជាតិរបស់ប្រទេសទទួលពលករទេសន្តរប្រវេសន៍មានសិទ្ធិទទួលបានមិនតិចជាងច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយប្រទេសទទួលនោះអនុវត្តចំពោះពលរដ្ឋរបស់ខ្លួននៅពេលដែលពួកគេត្រូវជាប់ពន្ធនាគារ ឬដាក់ក្នុងមន្ទីរឃុំឃាំងដែលកំពុងរង់ចាំការកាត់ក្តី ឬខណៈពេលកំពុងឃុំខ្លួនដោយហេតុផលផ្សេងទៀត"។

7. កិច្ចប្រជុំលើកទី៧ (២០១៤) លើកទី៨ (២០១៥) និងលើកទី១២ (២០១៩) វេទិកាអាស៊ានស្តីពីទេសន្តរប្រវេសន៍ការងារ (AFML) បានផ្តល់ការណែនាំស្តីពីពលករទេសន្តរប្រវេសន៍នេសាទ។ អនុសាសន៍ដែលបានពិភាក្សា និងអនុម័តដោយភាគីពាក់ព័ន្ធ រួមមានតម្រូវការកិច្ចសន្យាការងារដែលមានស្តង់ដារ ដើម្បីកំណត់លក្ខខណ្ឌការងារឱ្យច្បាស់លាស់ សិទ្ធិ និងការទទួលខុសត្រូវរបស់ពលករ និងនិយោជកទាំងបុរសនិងស្ត្រី រួមទាំងវិស័យដែលងាយរងគ្រោះ និងពិបាកទៅដល់ ដូចជាវិស័យនេសាទ (AFML លើកទី៧) បែងចែកធនធាន និងពង្រឹងការធ្វើអធិការកិច្ចការងារ ដើម្បីការងារសមរម្យ និងលក្ខខណ្ឌការងារនៅក្នុងវិស័យ និងកន្លែងការងារដែលងាយរងគ្រោះ និងពិបាកទៅដល់ ដូចជាវិស័យនេសាទ (AFML លើកទី៧ និងលើកទី៨) និងជំរុញការផ្លាស់ប្តូរពីការងារក្រៅផ្លូវការ ដូចជាក្នុងវិស័យនេសាទទៅជាការងារស្របច្បាប់ដើម្បីធានាបាននូវការការពារសិទ្ធិការងាររបស់ពលករទេសន្តរប្រវេសន៍ក្នុងវិស័យទាំងនេះ (AFML លើកទី១២)។

8. នៅឆ្នាំ២០១៩ សន្និសីទអធិការកិច្ចការងារអាស៊ានលើកទី៨ (ALIC) ក៏បានអនុម័តសេចក្តីសន្និដ្ឋាន និងអនុសាសន៍ស្តីពី "ការធានាការងារសមរម្យក្នុងវិស័យជលផលតាមរយៈអធិការកិច្ចការងារក្នុងអាស៊ាន" ដែលបានទទួលស្គាល់ថា ការនេសាទអាចជាមុខរបរគ្រោះថ្នាក់ ហើយពលករទេសន្តរប្រវេសន៍នេសាទងាយរងគ្រោះពីការបាត់បង់ការងារដ៏សមរម្យ រួមទាំងលក្ខខណ្ឌការងារដែលមិនអាចទទួលយកបាន និងជីវភាពរស់នៅលើនាវានេសាទរយៈពេលយូរហួសកម្រិត ប្រាក់ចំណូលទាប ភាពឯកោនៅលើដែនសមុទ្រ និងការអនុវត្តការជ្រើសរើសបុគ្គលិកមានលក្ខណៈរំលោភបំពាន រួមជាមួយនឹងអធិការកិច្ចការងារជាទូទៅមិនបានគ្រប់គ្រាន់ ។ ជាពិសេស សន្និសីទអធិការកិច្ចការងារអាស៊ាន (ALIC) លើកទី៨ បានទទួលស្គាល់ពីតម្រូវការដើម្បី "ចាត់វិធានការដ៏សមស្របកំណត់អត្តសញ្ញាណ និងដោះស្រាយការរំលោភបំពានដែលពលករទេសន្តរប្រវេសន៍ប្រឈមមុខក្នុងវិស័យនេសាទ ដោយផ្អែកលើគោលការណ៍ទូទៅ និងគោលការណ៍ណែនាំប្រតិបត្តិការសម្រាប់ការជ្រើសរើសដោយយុត្តិធម៌របស់អង្គការអន្តរជាតិខាងការងារ (ILO)។[2] វិធានការទាំងនោះអាចរួមបញ្ចូលការសម្របសម្រួលកាន់តែប្រសើរឡើងរវាងក្រុមអធិការកិច្ចការងារនៅប្រទេសបញ្ជូន និងប្រទេសទទួល ការអនុវត្តច្បាប់ពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាពលើតួអង្គទាំងអស់ក្នុងដំណើរការជ្រើសរើស ការចូលរួមកាន់តែច្រើនជាមួយសហគមនពលករទេសន្តរប្រវេសន៍នេសាទ និងគោលនយោបាយច្បាស់លាស់ និងមានប្រសិទ្ធភាពសម្រាប់ដោះស្រាយករណី និងការបញ្ជូនត្រឡប់មកប្រទេសវិញ" (មាត្រាទី៧)។

9. អនុលោមតាមអនុសាសន៍ខាងលើ ការពង្រឹងប្រព័ន្ធអធិការកិច្ចការងារក្នុងវិស័យនេសាទឆ្ពោះទៅរកការងារសមរម្យ គឺជាអាទិភាពមួយនៅក្នុងក្រុមការងារស្តីពីការអនុវត្តការងារប្រកបដោយវឌ្ឍនភាព ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងផែនការការងារ ឆ្នាំ២០២១-២០២៥ របស់អាស៊ាន (SLOM-WG)។ ជាមួយគ្នានេះ គណៈកម្មាធិការអធិការកិច្ចការងារអាស៊ាន (ALICOM) ក៏ផ្តល់អាទិភាពដល់ការពង្រឹងការអធិការកិច្ចការងារក្នុងវិស័យដែលពិបាកចូលទៅដល់ រួមទាំងវិស័យនេសាទ និងប្រព័ន្ធបញ្ជូនបន្តដែលមានប្រសិទ្ធភាព និងអាចចូលប្រើប្រាស់បាន ដើម្បី បង្ការពលកម្មដោយបង្ខំ និងពលកម្មកុមារ។ នេះគឺជាវិស័យអាទិភាពមួយនៃផែនការការងាររបស់គណៈកម្មាធិការអធិការកិច្ចការងារអាស៊ាន ALICOM ឆ្នាំ ២០២២-២០៣០។

---

[2] ចូលមើលបានតាមរយៈ៖ https://www.ilo.org/global/topics/fair-recruitment/WCMS_536755

10. ក្នុងឆ្នាំ២០១៦ សេចក្តីថ្លែងការណ៍រួមអាស៊ាន និងមជ្ឈមណ្ឌលអភិវឌ្ឍន៍អាស៊ីអាគ្នេយ៍ (SEAFDEC) ស្តីពីកិច្ចសហប្រតិបត្តិការក្នុងតំបន់សម្រាប់ការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ដែលមិនមានការរាយការណ៍ និងការត្រួតពិនិត្យ និងការលើកកម្ពស់ការប្រកួតប្រជែងផលិតផលត្រី និងការនេសាទរបស់អាស៊ាន បានប្រកាសពីចេតនារបស់រដ្ឋសមាជិកអាស៊ាន និងមជ្ឈមណ្ឌលអភិវឌ្ឍន៍អាស៊ីអាគ្នេយ៍ ក្នុងការដោះស្រាយបញ្ហា "ពីការងារ (ការអនុវត្តប្រកបដោយសុវត្ថិភាព ភាពស្របច្បាប់ និងការអនុវត្តប្រកបដោយសមធម៌) ក្នុងវិស័យនេសាទក្នុងតំបន់អាស៊ីអាគ្នេយ៍ តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមទីភ្នាក់ងារថ្នាក់ជាតិពាក់ព័ន្ធក្នុងប្រទេស ក៏ដូចជាការបង្កើតកិច្ចសហប្រតិបត្តិការក្នុងតំបន់ អនុតំបន់ និងកិច្ចសហប្រតិបត្តិការទ្វេភាគី តាមរយៈវេទិកាអាស៊ានដែលពាក់ព័ន្ធ" (មាត្រាទី៩)។

11. លើសពីនេះ ប្រទេសឥណ្ឌូណេស៊ីបានដឹកនាំកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលក្នុងតំបន់ មុនពេលបង្កើតគោលការណ៍ណែនាំទាំងនេះ រួមទាំងសន្និសីទអាស៊ីអាគ្នេយ៍ស្តីពីការសម្របសម្រួលក្នុងតំបន់ និងសកម្មភាពដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មក្នុងវិស័យនេសាទដែលបានធ្វើឡើងក្នុងឆ្នាំ២០១៨ នៅកោះបាលី និងមានការចូលរួមពីពហុភាគីមកពីរដ្ឋសមាជិកអាស៊ាន ចំនួនប្រាំបី និងបន្តដោយសន្និសីទសមធម៌ការងារសមុទ្រ នៅកោះបាលី ប្រទេសឥណ្ឌូណេស៊ី ក្នុងខែកញ្ញា ឆ្នាំ២០២២ ដែលបានប្រមូលផ្តុំអ្នកពាក់ព័ន្ធត្រីភាគី និងភាគីពាក់ព័ន្ធមកពីរដ្ឋសមាជិកអាស៊ាន ពិភាក្សាអំពីការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព និងការងារសមរម្យក្នុងវិស័យនេសាទ និងការកែច្នៃអាហារសមុទ្រ។ លទ្ធផលសំខាន់នៃសន្និសីទគឺបង្កើតដំណោះស្រាយពេញអង្គមួយដែលបានទទួលស្គាល់ផ្នែកអាទិភាពមួយចំនួននៃការងារ រួមទាំងតម្រូវការសម្រាប់ការបន្តកិច្ចខិតខំប្រឹងប្រែងទ្វេភាគី និងពហុភាគី ដើម្បីដោះស្រាយបញ្ហាប្រឈមនៅក្នុងអភិបាលកិច្ចការងារទេសន្តរប្រវេសន៍ការងារតាមច្រករបៀងទេសន្តរប្រវេសន៍(កថាខណ្ឌទី១០) ហើយអ្នកចូលរួមបានប្តេជ្ញាចិត្តបន្តជួបប្រជុំជាទៀងទាត់ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការក្នុងតំបន់រវាងរដ្ឋសមាជិកអាស៊ាន ។

12. រដ្ឋសមាជិកអាស៊ាន ទាំងអស់ក៏បានផ្តួចផ្តើម ឬបញ្ចប់កិច្ចព្រមព្រៀងទ្វេភាគីរវាងគ្នាទៅវិញទៅមក និង/ឬជាមួយប្រទេសនៅក្រៅតំបន់ទាក់ទងនឹងការការពារពលករទេសន្តរប្រវេសន៍។

## II. គោលបំណងនៃគោលការណ៍ណែនាំ

13. ខាងក្រោមនេះជាគោលបំណងនៃគោលការណ៍ណែនាំ៖

- ពន្យល់លម្អិតអំពីសំណុំគោលការណ៍ណែនាំសម្រាប់រដ្ឋសមាជិកអាស៊ាន ស្តីពីគោលនយោបាយ យន្តការស្ថាប័ន កម្មវិធី និងសេវាកម្មដែលត្រូវការសម្រាប់ការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ ស្របតាមគោលការណ៍នៃឯកច្ឆន្ទភាពអាស៊ាន និងក្របខ័ណ្ឌអាស៊ានផ្សេងទៀត ហើយយកឯកសារយោងពីបទដ្ឋានអន្តរជាតិ និងបទដ្ឋានការងារអន្តរជាតិខាងការងារដែលពាក់ព័ន្ធ។

- ដើរតួនាទីជាមគ្គុទ្ទេសក៍របស់រដ្ឋសមាជិកអាស៊ាន និងភាគីពាក់ព័ន្ធទាំងអស់សម្រាប់ការរៀបចំគោលនយោបាយលម្អិត យុទ្ធសាស្ត្រ និងក្របខ័ណ្ឌសកម្មភាពគ្រប់ជ្រុងជ្រោយនៅថ្នាក់ជាតិ ទ្វេភាគី និងថ្នាក់តំបន់លើការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ។

- ពង្រឹងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋសមាជិកអាស៊ាន និងភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀតសម្រាប់ការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទពេញមួយវដ្តនៃការធ្វើទេសន្តប្រវេសន៍។

- បន្តលើកទឹកចិត្តយ៉ាងសកម្មដល់រដ្ឋាភិបាល និយោជក ទីភ្នាក់ងារជ្រើសរើសពលករ អង្គនិយោជក អង្គការកម្មករនិយោជិត សង្គមស៊ីវិល ស្ថាប័នឯកជន និងអង្គភាពពហុជាតិ និងភាគីពាក់ព័ន្ធដទៃទៀតជាបន្តបន្ទាប់ ដើម្បីបញ្ចូលគោលការណ៍ណែនាំទាំងនេះក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការការពារពលករទេសន្តរប្រវេសន៍នេសាទ។

## III. អ្នកគ្រោងប្រើប្រាស់ និងភាគីពាក់ព័ន្ធគោលដៅ

14. គោលការណ៍ណែនាំនេះមានគោលបំណងអនុវត្តចំពោះភាគីពាក់ព័ន្ធសំខាន់ៗ ដែលធ្វើការពាក់ព័ន្ធនឹងការធ្វើពលករទេសន្តរប្រវេសន៍នេសាទទៅក្នុងវិស័យនេសាទនៅក្នុងរដ្ឋសមាជិកអាស៊ាន ជាពិសេសៈ
    - ពលករទេសន្តរប្រវេសន៍នេសាទ និងក្រុមគ្រួសាររបស់ពួកគេ
    - រដ្ឋាភិបាលនៃរដ្ឋសមាជិកអាស៊ាន នៅថ្នាក់កណ្តាល និងមូលដ្ឋាន
    - និយោជក និងសមាគមនិយោជក
    - អង្គការកម្មករនិយោជិត
    - ទីភ្នាក់ងារជ្រើសរើសឯកជន ឬទីភ្នាក់ងារមុខរបរ
    - វិស័យឯកជន រួមទាំងការកែច្នៃអាហារសមុទ្រ
    - តួអង្គដែលពាក់ព័ន្ធនៅក្នុងប្រទេសដែលដាក់ទង់ជាតិ ប្រទេសដែលផ្តល់កំពង់ផែដល់កប៉ាល់ នៅក្រៅរដ្ឋសមាជិកអាស៊ានដែលទទួលពលករទេសន្តរប្រវេសន៍នេសាទពីរដ្ឋសមាជិកអាស៊ាន
    - ស្ថាប័នពាក់ព័ន្ធរបស់អាស៊ាននៅទូទាំងសសរស្តម្ភទាំងបី ដែលទទួលបន្ទុកលើពលករទេសន្តរប្រវេសន៍ សុខភាព សុខុមាលភាពសង្គម ផលផល អន្តោប្រវេសន៍ និងសិទ្ធិមនុស្ស[3]
    - ដៃគូសន្ទនាអាស៊ាន
    - ដៃគូអភិវឌ្ឍន៍ (ដូចជា អង្គការអន្តរជាតិ ម្ចាស់ជំនួយ)
    - បណ្ឌិតសភា និង
    - ភាគីពាក់ព័ន្ធផ្សេងទៀត (ដូចជា ប្រព័ន្ធផ្សព្វផ្សាយ សមាជិកសភា ជនភៀសខ្លួន)។

## IV. ប្រភព និងឯកសារយោងនៃគោលការណ៍ណែនាំ

លិខិតុបករណ៍ និងប្រភពខាងក្រោម (រួមជាមួយនឹងផែនការសកម្មភាពដែលពាក់ព័ន្ធ) ត្រូវបានចាត់ទុកជាប្រភពឯកសារដែលមានប្រយោជន៍សម្រាប់ការយោងទៅលើ និងពន្យល់លម្អិតអំពីគោលការណ៍ណែនាំ និងនៅក្នុងការអនុវត្តជាបន្តបន្ទាប់របស់ពួកគេដោយរដ្ឋសមាជិកអាស៊ាន និងភាគីពាក់ព័ន្ធ។

15. លិខិតុបករណ៍អាស៊ានៈ
    - ធម្មនុញ្ញអាស៊ាន
    - ចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ ២០២៥
    - សេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីសិទ្ធិមនុស្ស
    - សេចក្តីថ្លែងការណ៍សេប៊ូ ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ឆ្នាំ២០០៧ (សេចក្តីថ្លែងការណ៍សេប៊ូ Cebu)
    - ឯកច្ឆន្ទភាពអាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ឆ្នាំ២០១៧ (ឯកច្ឆន្ទភាពអាស៊ាន)
    - សេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ
    - សេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការពង្រឹងកិច្ចការពារសង្គម
    - សេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីចល័តភាពអត្ថប្រយោជន៍នៃរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ក្នុងអាស៊ាន
    - សេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការការពារពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសារដែលស្ថិតក្នុងស្ថានភាពមានវិបត្តិ

[3] គណៈកម្មធិការអាស៊ានស្តីពីការអនុវត្តសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ (ACMW), គណៈកម្មាធិការអធិការកិច្ចការងារអាស៊ាន (ALICOM), កិច្ចប្រជុំឧត្តមមន្ត្រីការងារ (SLOM), កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីសុខុមាលភាពសង្គម និងការអភិវឌ្ឍ (SOMSWD), កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីការអភិវឌ្ឍផ្នែកសុខាភិបាល (SOMHD), ក្រុមការងារតាមវិស័យអាស៊ានស្តីពីជលផល (ASWGFi), ក្រុមការងារដឹកជញ្ជូនតាមសមុទ្រអាស៊ាន (MTWG), កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់អាស៊ាន (ASLOM), គណៈកម្មាធិការអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ (ACDM), អគ្គនាយកដ្ឋានអន្តោប្រវេសន៍អាស៊ាន និងប្រធានផ្នែកកិច្ចការកុងស៊ុលនៃក្រសួងការបរទេស (DGICM), គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) និងគណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC)។

គោលការណ៍ណែនាំអាស៊ានស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ប្រកបដោយប្រសិទ្ធភាព

- សេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីសិទ្ធិកុមារក្នុងបរិបទនៃការធ្វើទេសន្តរប្រវេសន៍
- ផែនទីបង្ហាញផ្លូវអាស៊ាន ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅឆ្នាំ២០២៥
- អនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ (ACTIP)
- សេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី និងការលុបបំបាត់អំពើហិង្សាលើកុមារនៅក្នុងអាស៊ាន
- គោលការណ៍ណែនាំអាស៊ាន ស្តីពីទំនួលខុសត្រូវសាជីវកម្មសង្គមសម្រាប់ការងារ
- គោលការណ៍ណែនាំអាស៊ាន ស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយការងារ និងឆ្ពោះទៅរកការងារសមរម្យសម្រាប់ទាំងអស់គ្នា
- អនុសាសន៍នៃវេទិកាអាស៊ាន ស្តីពីទេសន្តរប្រវេសន៍ការងារ (AFML)
- អនុសាសន៍នៃសន្និសីទអធិការកិច្ចការងារអាស៊ាន (ALIC)
- សេចក្តីថ្លែងការណ៍រួមរបស់អាស៊ាន និងមជ្ឈមណ្ឌលអភិវឌ្ឍន៍អាស៊ីអាគ្នេយ៍ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងតំបន់សម្រាប់ប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ ដែលមិនមានការរាយការណ៍ និងការត្រួតពិនិត្យ និងការលើកកម្ពស់សមត្ថភាពការប្រកួតប្រជែងផលិតផលត្រី និងការនេសាទអាស៊ាន

16. អង្គការសហប្រជាជាតិ និងលិខិតុបករណ៍ពាក់ព័ន្ធផ្សេងទៀត៖

- សេចក្តីថ្លែងការណ៍ជាសកល ស្តីពីសិទ្ធិមនុស្ស។
- អនុសញ្ញាអន្តរជាតិ ស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេទាំងអស់ (ICRMW)។
- អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW)។
- អនុសញ្ញា ស្តីពីសិទ្ធិកុមារ (CRC)។
- អនុសញ្ញា ស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន និងពិធីសារ Palermo ឆ្នាំ២០០០។
- អនុសញ្ញា ស្តីពីសេរីភាពក្នុងការបង្កើតជាសមាគម ឆ្នាំ១៩៤៨(C-ILO លេខ 87)។
- អនុសញ្ញា ស្តីពីសិទ្ធិក្នុងការបង្កើតសមាគម និងចរចាជាសមូហភាពឆ្នាំ ១៩៤៩ (C-ILO លេខ 98)។
- អនុសញ្ញា ស្តីពីពលកម្មដោយបង្ខំឆ្នាំ១៩៣០ (C-ILO លេខ ២៩) (និងពិធីសារឆ្នាំ ២០១៤)។
- អនុសញ្ញា ស្តីពីការលុបបំបាត់ការងារដោយបង្ខំឆ្នាំ១៩៥៧ (C-ILO លេខ ១០៥)។
- អនុសញ្ញា ស្តីពីអាយុអប្បបរមាឆ្នាំ ១៩៧៣ (C-ILO លេខ ១៣៨)។
- អនុសញ្ញា ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឆ្នាំ ១៩៩៩ (C-ILO លេខ ១៨២)។
- អនុសញ្ញា ស្តីពីប្រាក់ឈ្នួលស្មើគ្នា ឆ្នាំ ១៩៥១ (C-ILO លេខ ១០០)។
- អនុសញ្ញា ស្តីពីការរើសអើង (មុខរបរ និងការងារ) ឆ្នាំ១៩៥៨ (C-ILO លេខ ១១១)។
- អនុសញ្ញា ស្តីពីសុវត្ថិភាព និងសុខភាពការងារ ឆ្នាំ ១៩៨១ (C-ILO លេខ ១៥៥)។
- ក្របខ័ណ្ឌការងារផ្សព្វផ្សាយសម្រាប់អនុសញ្ញា ស្តីពីសុវត្ថិភាព និងសុខភាពការងារ ឆ្នាំ ២០០៦ (C-ILO លេខ ១៨៧)។
- អនុសញ្ញា ស្តីពីទីភ្នាក់ងារការងារឯកជនឆ្នាំ ១៩៩៧ (C-ILO លេខ ១៨១)។
- អនុសញ្ញា ស្តីពីការធ្វើធ្វើទេសន្តរប្រវេសន៍ការងារ (កែសម្រួល), ឆ្នាំ ១៩៤៩ (C-ILO លេខ ៩៧)។
- អនុសញ្ញា ស្តីពីពលករទេសន្តរប្រវេសន៍ (បទប្បញ្ញត្តិបំពេញបន្ថែម) ឆ្នាំ ១៩៧៥ (C-ILO លេខ ១៤៣)។
- អនុសញ្ញា ស្តីពីអធិការកិច្ចការងារឆ្នាំ១៩៤៧ (C-ILO លេខ ៨១)។
- អនុសញ្ញា ស្តីពីរបបសន្តិសុខសង្គម (បទដ្ឋានអប្បបរមា) ឆ្នាំ១៩៥២ (C-ILO លេខ ១០២)។
- អនុសញ្ញា ស្តីពីអំពើហិង្សា និងការបៀតបៀនឆ្នាំ ២០១៩ (C-ILO លេខ ១៩០)។
- អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ។
- អនុសញ្ញាអន្តរជាតិ ស្តីពីបទដ្ឋាននៃការបណ្តុះបណ្តាល ការផ្តល់វិញ្ញាបនបត្រ និងការឃ្លាំមើលសម្រាប់បុគ្គលិកលើនាវានេសាទ (STCW-F) ឆ្នាំ ១៩៩៥។
- កិច្ចព្រមព្រៀងទីក្រុងខេប Cape Town ឆ្នាំ ២០១២។

17. អង្គការសហប្រជាជាតិ និងក្របខ័ណ្ឌដែលមិនជាប់កាតព្វកិច្ច និងការណែនាំផ្សេងទៀត៖

- ក្របខ័ណ្ឌពហុភាគីរបស់អង្គការអន្តរជាតិខាងការងារ (ILO) ស្តីពីការធ្វើទេសន្តរប្រវេសន៍ការងារ។
- សេចក្តីថ្លែងការណ៍របស់អង្គការ ILO ស្តីពីគោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ។
- គោលការណ៍ទូទៅរបស់អង្គការ ILO និងគោលការណ៍ណែនាំប្រតិបត្តិការសម្រាប់ការជ្រើសរើសបុគ្គលិកដោយយុត្តិធម៌ និងនិយមន័យតម្លៃសេវាជ្រើសរើស និងការចំណាយពាក់ព័ន្ធ។
- របៀបវារៈឆ្នាំ ២០៣០ របស់អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។
- កតិកាសញ្ញាសកលឆ្នាំ ២០១៨ ស្តីពីការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM)។
- គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ឆ្នាំ២០១១៖ ការអនុវត្តក្របខ័ណ្ឌ "ការពារ គោរព និងដោះស្រាយ។

## V. គោលការណ៍ណែនាំទូទៅ

18. គោលការណ៍ទូទៅដែលត្រូវបានដកស្រង់ពីប្រភពផ្សេងៗ ដូចជាលិខិតុបករណ៍អន្តរជាតិ បទដ្ឋាន និងក្របខ័ណ្ឌអន្តរជាតិខាងការងារ ក្របខ័ណ្ឌសកល និងអាស៊ាន គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងកតិកាសញ្ញាសកល ស្តីពីការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់– កំណត់ក្នុងផ្នែកទី IV ។ គោលការណ៍ណែនាំទូទៅខាងក្រោមមានតួនាទីជាក្របខ័ណ្ឌ និងមូលដ្ឋានគ្រឹះទូទៅសម្រាប់គោលការណ៍ណែនាំ និងយុទ្ធសាស្ត្ររួមចំណែកដែលមានចែងខាងក្រោម។ ការគោរពដល់ការអនុវត្តគោលការណ៍ទូទៅ ធានាបាននូវសង្គតិភាព និងគោលនយោបាយស្របគ្នានៃវិធានការនានារបស់គោលការណ៍ដែលបានគូសបញ្ជាក់ក្រោមគោលការណ៍ណែនាំ។ គោលការណ៍ណែនាំតំណាងឱ្យវិធានការប្រតិបត្តិ និងអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព ដែលអាចត្រូវបានបង្កើតឡើងនៅក្នុងក្របខ័ណ្ឌលម្អិតនៃបទដ្ឋានសកល និងតំបន់។

### V.1. ការផ្អែកលើមូលដ្ឋាននៃសិទ្ធិ និងស្របតាមបទដ្ឋានអាស៊ាន និងអន្តរជាតិ

19. គោលនយោបាយ និងកម្មវិធីទាំងអស់គួរតែបញ្ជ្រាបការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទទៅក្នុងគោលនយោបាយ យន្តការ និងដំណើរការស្តីពីការធ្វើទេសន្តរប្រវេសន៍ដែលពាក់ព័ន្ធទាំងអស់របស់រដ្ឋសមាជិកអាស៊ាន ដោយគោរពសិទ្ធិមនុស្ស និងសិទ្ធិការងាររបស់ពលករទេសន្តរប្រវេសន៍នេសាទ និងក្រុមគ្រួសារដែលរស់នៅជាមួយ និងស្របតាមលិខិតុបករណ៍អាស៊ាន និងយោងតាមបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ និងលិខិតុបករណ៍អាស៊ាន។ សិទ្ធិមនុស្សជាសកល ត្រូវបានបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍ ស្តីពីសិទ្ធិមនុស្សអាស៊ានដែលចែងក្នុងគោលការណ៍ទូទៅទី៤ ថា "សិទ្ធិរបស់ស្ត្រី កុមារ មនុស្សចាស់ ជនដែលមានពិការភាព ពលករទេសន្តរប្រវេសន៍ និងក្រុមងាយរងគ្រោះ និងនិងបាត់បង់ឱកាស គឺជាផ្នែកមួយដែលមិនអាចកាត់ផ្តាច់បាន មានសារៈសំខាន់ និងមិនអាចផ្តាច់ចេញពីផ្នែកនៃសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន" ហើយនៅក្នុងគោលការណ៍ទូទៅទី ៧ចែងថា "សិទ្ធិមនុស្សទាំងអស់មានលក្ខណៈជាសកល មិនអាចបំបែកបាន ពឹងពាក់គ្នាទៅវិញទៅមក និងមានទំនាក់ទំនងគ្នា"។

20. គោលការណ៍ទូទៅដំបូងនៃសេចក្តីថ្លែងការណ៍សេប៊ូ Cebu ឆ្នាំ២០០៧ ចែងថា "ទាំងប្រទេសទទួល និងប្រទេសបញ្ជូនត្រូវពង្រឹងសសរស្តម្ភនយោបាយ សេដ្ឋកិច្ច និងសង្គមនៃសហគមន៍អាស៊ាន ដោយលើកកម្ពស់សក្តានុពល និងសេចក្តីថ្លៃថ្នូរពេញលេញរបស់ពលករទេសន្តរប្រវេសន៍ក្នុងបរិយាកាសប្រកបដោយសេរីភាព សមធម៌ និងស្ថិរភាព"។ គោលការណ៍ទូទៅនៃឯកច្ឆន្ទភាពអាស៊ានឆ្នាំ២០១៧ ក៏មានចែងផងដែរថា ៖ រដ្ឋសមាជិកអាស៊ានរក្សាសិទ្ធិ និងសេចក្តីថ្លៃថ្នូរជាមូលដ្ឋានរបស់ពលករទេសន្តរប្រវេសន៍។

### V.2. ការមិនរើសអើង និងប្រព្រឹត្តកម្មដោយស្មើភាព

21. គោលការណ៍ស្តីពីការមិនរើសអើងត្រូវអនុវត្តលើគ្រប់ទិដ្ឋភាពនៃការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីសិទ្ធិមនុស្ស ចែងថា "មនុស្សទាំងអស់គ្នាមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិដោយគ្មានការរើសអើងក្នុងការទទួលបានការការពារស្មើគ្នាពីច្បាប់"។ របៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅ ៨.៥៖ ការងារពេញលេញ និងការងារសមរម្យដែលមានប្រាក់ឈ្នួលស្មើគ្នា និងគោលដៅ ៨.៨៖ ការពារសិទ្ធិការងារ និងលើកកម្ពស់បរិយាកាសការងារដែលមានសុវត្ថិភាព។ អនុសញ្ញាស្តីពីការរើសអើងរបស់ អង្គការអន្តរជាតិខាងការងារ (មុខរបរ និងការងារ) ឆ្នាំ១៩៥៨ ឱ្យនិយមន័យការរើសអើងថាជា "ភាពខុសគ្នា ការបដិសេធ ឬចំណូលចិត្តដែលធ្វើឡើងដោយឈរលើមូលដ្ឋាននៃជាតិសាសន៍ ពណ៌សម្បុរ ភេទ សាសនា ទស្សនៈនយោបាយ ខ្សែស្រឡាយ ឬប្រភពដើមនៃសង្គម ដែលមានឥទ្ធិពលធ្វើឱ្យប៉ះពាល់ដល់សមភាពនៃឱកាស ឬប្រព្រឹត្តកម្មក្នុងមុខរបរ ឬការងារ"។ សេចក្តីប្រកាសរបស់អង្គការអន្តរជាតិខាងការងារ ស្តីពីគោលការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ រួមមានការលុបបំបាត់ការរើសអើងទាក់ទងនឹងការងារ និងមុខរបរជាសិទ្ធិមូលដ្ឋាន។ មាត្រា៧ នៃឯកច្ឆន្ទភាពអាស៊ានឱ្យនិយមន័យការប្រព្រឹត្តដោយស្មើភាពថាជាការអនុវត្តដោយយុត្តិធម៌ និងសមហេតុផលដែលអនុវត្តចំពោះពលករទេសន្តរប្រវេសន៍នៅកន្លែងធ្វើការទាក់ទងនឹងលក្ខខណ្ឌការងារ សុវត្ថិភាព និងការទទួលបានសិទ្ធិទទួលបានជំនួយ។ មាត្រា៨ នៃសេចក្តីថ្លែងការណ៍សេប៊ូ Cebu តម្រូវឱ្យប្រទេសទទួលមានតួនាទីលើកកម្ពស់ការការពារការងារដោយស្មើភាព និងសមរម្យ ការ

ទូទាត់ប្រាក់ឈ្នួល និងការទទួលបានសិទ្ធិទទួលបានការងារ និងជីវភាពសមរម្យសម្រាប់ពលករទេសន្តរប្រវេសន៍។ គោលការណ៍នៃការមិនរើសអើង ក៏មាននៅក្នុងអនុសាសន៍នៃវេទិកាអាស៊ាន ស្តីពីទេសន្តរប្រវេសន៍ការងារ លើកទី១៤ និងទី១៥ ដែលអំពាវនាវឱ្យមានការប្រព្រឹត្តដោយស្មើភាព និង មិនរើសអើងចំពោះពលករទេសន្តរប្រវេសន៍។

### V.3. ការគិតគូរពីយេនឌ័រ និងការឆ្លើយតបចំពោះយេនឌ័រ

22. ការគិតគូរពីយេនឌ័រ មានន័យថា ការទទួលស្គាល់ និងដឹងពីភាពខុសគ្នានៃតួនាទី តម្រូវការ និងទស្សនៈរបស់ស្ត្រី និងបុរស អតុល្យភាពដែលអាចកើតមាននៅក្នុងទំនាក់ទំនងរបស់ពួកគេ និងសកម្មភាព ឬកិច្ចអន្តរាគមន៍អាចនឹងទទួលបានលទ្ធផលខុសៗគ្នាសម្រាប់ស្ត្រី និងបុរសដោយផ្អែកលើភេទ និងអត្តសញ្ញាណរបស់ពួកគេ ប៉ុន្តែមិនស្វែងរកវិធីសាស្ត្រដើម្បីដោះស្រាយបញ្ហាទាំងនេះយ៉ាងជាក់លាក់ទេ។ ការឆ្លើយតបចំពោះយេនឌ័រ មានន័យថាលើសពីការគិតគូរយេនឌ័រដោយធ្វើការវិនិច្ឆ័យ និងការយល់ដឹងអំពីភាពខុសគ្នារវាងយេនឌ័រ ដើម្បីរៀបចំ គោលនយោបាយ សកម្មភាព និងគំនិតផ្តួចផ្តើមជាក់លាក់ ដើម្បីដោះស្រាយសមភាពយេនឌ័រដែលបានកំណត់តាមរយៈការប្រើប្រាស់ការវិភាគទិន្នន័យដែលមានការបែកចែកតាមភេទ និងព័ត៌មានទាក់ទងយេនឌ័រ។ [4]

23. យេនឌ័រអាចត្រូវបានកំណត់ក្នុងការជ្រើសរើស លក្ខខណ្ឌការងារ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍នេសាទអំពើហិង្សាដែលពួកគេប្រឈម និងលទ្ធផលនៃការធ្វើទេសន្តរប្រវេសន៍។ អ្នកបង្កើតគោលនយោបាយអាស៊ាន និងភាគីពាក់ព័ន្ធផ្សេងទៀតគួរតែធានាថា រាល់អន្តរាគមន៍ពាក់ព័ន្ធនឹងការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ គឺជាការគិតគូរអំពីយេនឌ័រ និងការឆ្លើយតបចំពោះយេនឌ័រ។ មាត្រា ១ (ង) នៃឯកច្ឆន្ទភាពអាស៊ាន ចែងថា រដ្ឋសមាជិកអាស៊ាន នឹងរក្សាការប្រព្រឹត្តដោយស្មើភាពទាក់ទងនឹងយេនឌ័រ និងសញ្ជាតិ ព្រមទាំងការការពារ និងការលើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ ជាពិសេសស្ត្រី។

### V.4. បរិយាបន្ន និងជំនួយចំគោលដៅ សម្រាប់ពលករទេសន្តរប្រវេសន៍នេសាទ រួមទាំងពលករទេសន្តរប្រវេសន៍ដែលមិនមានឯកសារគ្រប់គ្រាន់ និងពលករទេសន្តរប្រវេសន៍ដែលមានវិបត្តិ

24. គោលនយោបាយ និងកម្មវិធីទាំងអស់ស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេស៍នេសាទ គួរតែសង្កត់ធ្ងន់លើការគាំទ្រដែលមានគោលដៅ និងបរិយាបន្នសម្រាប់ពលករទេសន្តរប្រវេសន៍នេសាទ រួមទាំងពលករទេសន្តរប្រវេសន៍ដែលគ្មានកំហុសបានក្លាយទៅជាពលករមិនមានឯកសារគ្រប់គ្រាន់ និងជាពលករទេសន្តរប្រវេសន៍ស្ថិតក្នុងស្ថានភាពដែលមានវិបត្តិ។ ពលករទេសន្តរប្រវេសន៍នេសាទ ជារឿយៗត្រូវបានជួលឱ្យធ្វើការក្រៅផ្លូវការ ឬមានស្ថានភាពមិនប្រក្រតី ដោយស្ថិតក្រោមការរឹតត្បិតក្នុងការប្រើប្រាស់ការប្រាស្រ័យទាក់ទង ការរាយការណ៍ និងវិធីបញ្ជូនបន្ត និងជាលទ្ធផលអាចប្រឈមការរំលោភបំពាន និងការកេងប្រវ័ញ្ច ដោយសារលក្ខណៈស្ថានភាពពិបាកចូលឱ្យដល់ មានគ្រោះថ្នាក់ និងបរិយាកាសអាចមានគ្រោះថ្នាក់។ ឯកច្ឆន្ទភាពអាស៊ាន តម្រូវឱ្យ រដ្ឋសមាជិកអាស៊ាន សហការដើម្បីដោះស្រាយករណីពលករទេសន្តរប្រវេសន៍ដែលបានក្លាយទៅជាពលករមិនមានឯកសារគ្រប់គ្រាន់ ដោយមិនមែនជាកំហុសរបស់ពួកគេ (មាត្រា២) និងសហការ និងសម្របសម្រួលដើម្បីផ្តល់ជំនួយដល់ពលករទេសន្តរប្រវេសន៍ដែលជាប់ក្នុងស្ថានភាពមានជម្លោះ ឬវិបត្តិ (មាត្រា ៥៥)។ សេចក្តីថ្លែងការណ៍របស់អាស៊ានស្តីពីការដាក់ឱ្យធ្វើធ្វើការ និងការការពារអ្នកនេសាទចំណាកស្រុក ប្តេជ្ញាពង្រឹងវិធានការផ្តល់ជំនួយមនុស្សធម៌ក្នុងករណីមានវិបត្តិដល់ពលករទេសន្តរប្រវេសន៍នេសាទ។

---

[4] និយមន័យផ្អែកលើគោលការណ៍ណែនាំអាស៊ានស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយមុខរបរ និងការងារឆ្ពោះទៅរកការងារសមរម្យសម្រាប់ទាំងអស់គ្នា (ឆ្នាំ ២០២១)។

## V.5. តម្លាភាព សុចរិតភាព និងគណនេយ្យភាព

25. តម្លាភាព សុចរិតភាព និងគណនេយ្យភាព គឺជាគុណតម្លៃស្នូលដែលគោលនយោបាយនិងកម្មវិធីទាំងអស់គួរតែរួមបញ្ចូល។ កត្តាសំខាន់នៃអភិបាលកិច្ចល្អ គោលការណ៍តម្លាភាព សុចរិតភាព និងគណនេយ្យភាព គួរតែបញ្ជាក់គ្រប់ទិដ្ឋភាពនៃការងារស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ ។ ក្នុងឯកច្ឆន្ទភាពអាស៊ាន រដ្ឋសមាជិកអាស៊ាន បានបញ្ជាក់ជាថ្មីនូវការប្រកាន់ខ្ជាប់របស់ខ្លួននូវគោលការណ៍អភិបាលកិច្ចល្អ។ គោលនយោបាយ និងបទប្បញ្ញត្តិទាក់ទងនឹងការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ គួរតែត្រូវបានសរសេរឱ្យបានច្បាស់លាស់ ដើម្បីធានាឱ្យបានថាគោលនយោបាយ និងបទប្បញ្ញត្តិទាំងនេះត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាដោយពលករទេសន្តរប្រវេសន៍នេសាទ ប្រទេសទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យសហការក្នុងការប្រមូលទិន្នន័យ និងការចែករំលែកទិន្នន័យដើម្បីការពារពលករទេសន្តរប្រវេសន៍នេសាទ ឱ្យកាន់តែប្រសើរឡើងតាមលក្ខណៈដែលគោរពឯកជនភាព និងសុវត្ថិភាពរបស់ពួកគេ ហើយពលករទេសន្តរប្រវេសន៍នេសាទ និងក្រុមគ្រួសាររបស់ពួកគេគួរតែមានសិទ្ធិទទួលបានព័ត៌មានដែលពួកគេត្រូវការយ៉ាងពេញលេញ រួមទាំងសេវាកម្ម និងកម្មវិធីដែលមានសម្រាប់ពួកគេ។ សុចរិតភាពសំដៅដល់ការអនុវត្តការប្រកាន់ខ្ជាប់ និងរក្សានូវគោលការណ៍សីលធម៌ដ៏រឹងមាំដូចជា ភាពស្មោះត្រង់ និងសេរីភាពពីអំពើពុករលួយ ប្រព័ន្ធសុចរិតភាពល្អដែលត្រូវបានបង្កើតឡើងនៅក្នុងកម្មវិធីជំនួយ អាចទប់ស្កាត់អំពើពុករលួយ និងការប្រើប្រាស់ធនធានមិនត្រឹមត្រូវ។ លក្ខណៈទាំងនោះក៏នាំឱ្យមានគណនេយ្យភាពពីអ្នកគ្រប់គ្រងកម្មវិធី។ គណនេយ្យភាពពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យ និងការរាយការណ៍អំពីភាពជោគជ័យ និងបញ្ហាប្រឈមនៃគោលនយោបាយ និងកម្មវិធីស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ។

## V.6. ការចូលរួម ភាពជាតំណាង សិទ្ធិបញ្ចេញមតិ និងទីភ្នាក់ងាររបស់ពលករទេសន្តរប្រវេសន៍នេសាទ

26. គោលនយោបាយ និងកម្មវិធីស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ គួរតែគិតដល់ពលករទេសន្តរប្រវេសន៍នេសាទគ្រួសាររបស់ពួកគេដែលរស់នៅជាមួយពួកគេរួចហើយ និងសមាគមរបស់ពួកគេតាមរយៈការពិគ្រោះយោបល់ និងការចូលរួមក្នុងការសន្ទនាសង្គមដើម្បីដាក់បញ្ចូលតម្រូវការរបស់ពួកគេ។ ពលករទេសន្តរប្រវេសន៍នេសាទ ក៏អាចរៀបចំ និងចូលរួមក្នុងការចរចាជាសមូហភាពផងដែរ ស្របតាមច្បាប់ជាតិ បទប្បញ្ញត្តិ និងគោលនយោបាយរបស់រដ្ឋសមាជិកអាស៊ាន។ សិទ្ធិរបស់ពលករពលករទេសន្តរប្រវេសន៍ក្នុងការចូលរួមសហជីព និងបង្កើតសមាគមត្រូវបានទទួលស្គាល់នៅក្នុងឯកច្ឆន្ទភាពអាស៊ាន។

## V.7. វិធីសាស្ត្ររដ្ឋាភិបាលទាំងមូល និងសង្គមទាំងមូល

27. វិធីសាស្ត្ររដ្ឋាភិបាលទាំងមូល និងសង្គមទាំងមូល គឺជាគោលការណ៍ណែនាំដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា និងប្រាស្រ័យគ្នាទៅវិញទៅមក។ វិធីសាស្ត្ររដ្ឋាភិបាលទាំងមូលត្រូវបានបង្ហាញថាជាការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយស្តីពីការធ្វើទេសន្តប្រវេសន៍ប្រកបដោយប្រសិទ្ធភាព ដែលធានាបាននូវភាពស៊ីសង្វាក់គ្នានៃគោលនយោបាយផ្តេក និងបញ្ឈរនៅគ្រប់វិស័យ និងគ្រប់កម្រិតរបស់រដ្ឋាភិបាល។ ការងារនេះពាក់ព័ន្ធជាពិសេសទៅនឹងគោលនយោបាយស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ ដែលមានអន្តរកម្មជាមួយក្រសួង និងនាយកដ្ឋានមួយចំនួនរបស់រដ្ឋាភិបាល។ វិធីសាស្ត្រសង្គមទាំងមូលគឺជាវិធីសាស្ត្រពហុភាគីដែលធានាថាដៃគូ ដែលតំណាងឱ្យគ្រប់ផ្នែកនៃការធ្វើទេសន្តប្រវេសន៍ទៅក្នុងវិស័យនេសាទ រួមមាន រដ្ឋាភិបាល និយោជិត និយោជក ភាគីពាក់ព័ន្ធ តួអង្គក្នុងខ្សែច្រវ៉ាក់ផ្គត់ផ្គង់ និងភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ត្រូវបានពិគ្រោះយោបល់ក្នុងការរចនា ការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយ។

V.8. គោលការណ៍ទំនួលខុសត្រូវរួមរវាងប្រទេសបញ្ជូន និងប្រទេសទទួល

28. បុព្វកថានៃឯកច្ឆន្ទភាពអាស៊ានលើកឡើងថា "ការបញ្ជាក់ពីការបែងចែកការទទួលខុសត្រូវរួម និងមានតុល្យភាពរបស់រដ្ឋសមាជិកអាស៊ាន ដែលទទួល និងដែលបញ្ជូន ដើម្បីការពារ និងលើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេក្នុងដំណើរការធ្វើទេសន្តរប្រវេសន៍ទាំងមូល"។ សម្រាប់ការការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ ការទទួលខុសត្រូវរួមនេះត្រូវបានពង្រីកទៅរដ្ឋកំពង់ផែ រដ្ឋឆ្នេរសមុទ្រ និងរដ្ឋដែលបោះទង់ជាតិ។ គោលការណ៍នេះត្រូវបានពង្រីកបន្ថែមទៀតដល់តួអង្គនៅក្នុងខ្សែច្រវ៉ាក់ផ្គត់ផ្គង់ ដើម្បីធានាថាតួអង្គទាំងអស់ដែលចូលរួម និងទទួលបានអត្ថប្រយោជន៍ពីការងាររបស់ពលករទេសន្តរប្រវេសន៍នេសាទ មានទំនួលខុសត្រូវចំពោះការងារ និងសិទ្ធិមនុស្ស និងសុខុមាលភាពរបស់ពួកគេ។ ជាពិសេស ភាគីពាក់ព័ន្ធគួរតែពង្រីកកន្លែងសម្រាប់កិច្ចសន្ទនាសង្គម និងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសមភាគីក្នុងរដ្ឋដែលដើរតួនាទីផ្សេងគ្នា (ដូចជា តំបន់ឆ្នេរសមុទ្រទៅកាន់តំបន់កំពង់ផែ ប្រទេសបញ្ជូនទៅកាន់តំបន់ឆ្នេរសមុទ្រ)។

V.9. គោលនយោបាយ និងកម្មវិធីផ្អែកលើមូលដ្ឋានភស្តុតាង

29. គោលនយោបាយ និងកម្មវិធីស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទគួរតែផ្អែកលើមូលដ្ឋានភស្តុតាង។ ភស្តុតាងរួមមានការប្រមូលទិន្នន័យក្នុងដំណើរការនៃអភិបាលកិច្ចការធ្វើទេសន្តរប្រវេសន៍ ក៏ដូចជាការស្រាវជ្រាវគោលដៅលើបញ្ហាជាក់លាក់ចំពោះពលករទេសន្តរប្រវេសន៍នេសាទ។ នៅក្នុងការប្រមូលទិន្នន័យទាំងអស់ ចាំបាច់ត្រូវគោរពឯកជនភាពរបស់ពលករទេសន្តរប្រវេសន៍នេសាទ និងសមាជិកគ្រួសាររបស់ពួកគេ ការរក្សាការសម្ងាត់នៃទិន្នន័យដែលបានប្រមូល គោរពគោលការណ៍មិនបង្កគ្រោះថ្នាក់ និងគោលការណ៍តម្លាភាពដូចបានរៀបរាប់ខាងលើ ជាពិសេសពលករទេសន្តរប្រវេសន៍នេសាទ ដែលមានឯកសារមិនគ្រប់គ្រាន់។ ភស្តុតាងអាចត្រូវបានប្រើដើម្បីបញ្ជាក់ពីការអភិវឌ្ឍ និងវាយតម្លៃផលប៉ះពាល់នៃគោលនយោបាយ និងកម្មវិធីស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ ដោយធានាថាតម្រូវការអាទិភាពត្រូវបានកំណត់និងដោះស្រាយ។

V.10. ភាពជាដៃគូ និងកិច្ចសហការ

30. គោលការណ៍នៃភាពជាដៃគូ និងកិច្ចសហការគូសបញ្ជាក់អំពីតម្រូវការដើម្បីធ្វើការរួមគ្នាក្នុងការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ ។ លក្ខណៈនៃការធ្វើទេសន្តរប្រវេសន៍ និងវិស័យនេសាទមានន័យថាបញ្ហាឆ្លងអាណត្តិរបស់ភាគីពាក់ព័ន្ធដែលមានចែងក្នុងកថាខណ្ឌទី១៤។ ចលករ ការប្តេជ្ញាចិត្ត និងការផ្លាស់ប្តូរនឹងតម្រូវឱ្យមានភាពជាដៃគូ និងការសហការឆ្លងព្រំដែន ឆ្លងវិស័យ និងឆ្លងក្រុមភាគីពាក់ព័ន្ធ។

VI. គោលការណ៍ណែនាំរបស់អាស៊ានស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ

31. ការប្រើប្រាស់គោលការណ៍ណែនាំគឺធ្វើឡើងដោយការស្ម័គ្រចិត្ត និងមិនចងកាតព្វកិច្ចតាមផ្លូវច្បាប់នោះទេ។ ទោះជាយ៉ាងណាក្តីរដ្ឋសមាជិកអាស៊ានត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់គោលការណ៍ណែនាំនេះយ៉ាងទូលំទូលាយក្នុងការធ្វើឱ្យប្រសើរឡើងនូវកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ ទ្វេភាគី និងពហុភាគី ដើម្បីធានាថាការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទមានប្រសិទ្ធភាព គ្រប់ជ្រុងជ្រោយ មានបរិយាបន្ន និងនិរន្តរភាព និងត្រូវបានបង្កើតឡើងតាមរយៈកិច្ចសន្ទនាសង្គម។ ក្នុងការប្រើប្រាស់គោលការណ៍ណែនាំនេះរដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យសម្របសម្រួល និងសហការជាមួយភាគីពាក់ព័ន្ធក្នុងប្រទេសរបស់ខ្លួន និងរដ្ឋសមាជិកអាស៊ាន ផ្សេងទៀត ដូចដែលបានលើកឡើងក្នុងកថាខណ្ឌទី១៤។

VI.1. ក្របខ័ណ្ឌគតិយុត្ត

*VI.1.1 ពិនិត្យ និងពង្រឹងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាតិ សម្រាប់ការអនុលោមតាមបទដ្ឋានអន្តរជាតិដែលអាចអនុវត្តបាន*

32. ប្រសិនបើអាចធ្វើទៅបានរដ្ឋសមាជិកអាស៊ាន – រួមទាំងប្រទេសបញ្ជូន និងប្រទេសទទួល ព្រមទាំងរដ្ឋដែលដាក់ទង់ជាតិ រដ្ឋដែលមានកំពង់ផែ និងរដ្ឋដែលមានឆ្នេរផងដែរ – ត្រូវបានលើកទឹកចិត្តឱ្យធ្វើការវិភាគប្រៀបធៀបកម្រិតជាតិនៃក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាតិរបស់ពួកគេ និងយន្តការស្ថាប័ន ដោយសារវាទាក់ទងទៅនឹង ការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ ដើម្បីពិនិត្យឡើងវិញនូវវិសាលភាពដែលច្បាប់ និងគោលនយោបាយការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍នេសាទ នៅក្នុងវដ្តការធ្វើទេសន្តរប្រវេសន៍ទាំងមូល ដោយយោងលើបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ និងកំណត់គម្លាតណាមួយ។

33. ដោយផ្អែកលើការវិភាគប្រៀបធៀបរដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យចាត់វិធានការដើម្បីដោះស្រាយគម្លាតដែលបានកំណត់ និងពង្រឹងគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងយន្តការស្ថាប័នសម្រាប់ការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ ដើម្បីពង្រឹងការអនុលោមតាមបទដ្ឋានអន្តរជាតិ។ ជាពិសេសរដ្ឋសមាជិកអាស៊ាន នឹងជំរុញការផ្លាស់ប្តូរពីការងារក្រៅប្រព័ន្ធទៅជាការងារក្នុងប្រព័ន្ធស្របតាមអនុសាសន៍នៃវេទិកាអាស៊ានស្តីពីទេសន្តរប្រវេសន៍ការងារ លើកទី១២។

34. កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋសមាជិកនឹងរួមបញ្ចូលជាពិសេសក្នុងការពង្រឹងច្បាប់ និងគោលនយោបាយដើម្បីធ្វើឱ្យប្រសើរនូវលក្ខខ័ណ្ឌការងាររបស់ពលករទេសន្តរប្រវេសន៍នេសាទ និងធានានូវការការពារសិទ្ធិការងាររបស់ពួកគេ រួមទាំង(ប៉ុន្តែមិនកំណត់ចំពោះ)លក្ខខណ្ឌការងារ សុវត្ថិភាព និងសុខភាពការងារ អនាម័យ ការវាយតម្លៃហានិភ័យ សិទ្ធិទទួលបានយុត្តិធម៌ និងសិទ្ធិទទួលបានការការពារសន្តិសុខសង្គមដោយមានការយកចិត្តទុកដាក់ជាពិសេសក្នុងការផ្តល់សំណងដល់ពលករ (ឬសមាជិកគ្រួសាររបស់ពួកគេ) សម្រាប់ជំងឺ របួស ឬមរណភាព។

*VI.1.2. ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលឆ្លងព្រំដែនក្នុងការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ*

35. ក្នុងករណីចាំបាច់រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យផ្តួចផ្តើម និងបញ្ចប់កិច្ចព្រមព្រៀងទ្វេភាគី និងអនុស្សរណៈនៃការយោគយល់គ្នា និងជាមួយបណ្តាប្រទេសនៅក្រៅតំបន់ ដើម្បីជួយសម្រួលដល់ការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព និងស្របច្បាប់របស់ពលករនេសាទ ជាពិសេសក្នុងដំណើរការជ្រើសរើស និងការដាក់ឱ្យធ្វើការ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មឡើងវិញប្រកបដោយសុវត្ថិភាព និងសិទ្ធិទទួលបានយុត្តិធម៌ និងដំណោះស្រាយ។ ជាពិសេស កិច្ចព្រមព្រៀងទ្វេភាគី និងអនុស្សរណៈនៃការយោគយល់គ្នា គួរតែផ្តល់ឱ្យពលករទេសន្តរប្រវេសន៍នេសាទ នូវលទ្ធភាពទទួលបានសិទ្ធិការងារប្រកបដោយសមធម៌នូវសិទ្ធិការងារគ្រប់ជ្រុងជ្រោយ ការការពារសន្តិសុខសង្គម សិទ្ធិទទួលបានជនជាន និងដំណោះស្រាយប្រកបដោយសមធម៌។

36. យន្តការបញ្ជូនបន្តនៃការឆ្លើយតបនឹងយេនឌ័រត្រូវបានលើកទឹកចិត្តឱ្យបង្កើតឡើងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីដោះស្រាយបញ្ហាឆ្លងដែនទាក់ទងនឹងការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ និងការទទួលបានសេវា ដំណោះស្រាយ និងយុត្តិធម៌។ អនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយរបស់រដ្ឋសមាជិកអាស៊ាន យន្តការបែបនេះគួរតែកំណត់ និងធ្វើសកម្មភាពដោយមិនគិតពីថាតើពលករទេសន្តរប្រវេសន៍នេសាទ ស្ថិតនៅក្រោមយុត្តាធិការនៃប្រទេសបញ្ជូន ឬប្រទេសទទួល រដ្ឋដែលបោះទង់ជាតិ រដ្ឋដែលមានកំពង់ផែ ឬរដ្ឋដែលមានឆ្នេរសមុទ្រនោះទេ ដោយបង្កើតប្រព័ន្ធដែលដោះស្រាយបញ្ហាយុត្តាធិការទាក់ទងនឹងការទទួលបានយុត្តិធម៌ និងសេវាកម្មការពារផ្សេងទៀតដែលអាចមានដោយមិនគិតពីស្ថានភាពនៃការធ្វើទេសន្តរប្រវេសន៍របស់ពួកគេ។

37. ការសម្របសម្រួលឆ្លងព្រំដែនគួរតែជួយសម្រួលដល់ការផ្តល់សេវាកុងស៊ុល និង/ឬអនុព័ន្ធការងារដែលមានបរិយាបន្ន និងឆ្លើយតបទៅនឹងយេនឌ័រ ក្នុងការសម្រួលដល់ការចូលប្រើយន្តការបណ្តឹង និងការត្រឡប់មកប្រទេសវិញដោយស្ម័គ្រចិត្ត និងដោយសេចក្តីថ្លៃថ្នូរ។

*VI.1.3. ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលអន្តរក្រសួង និងការបញ្ជូនបន្តនៅថ្នាក់ជាតិ*

38. រដ្ឋសមាជិកអាស៊ាននីមួយៗត្រូវបានលើកទឹកចិត្តឱ្យលើកកម្ពស់ភាពស៊ីសង្វាក់គ្នានៃគោលនយោបាយ និងវិធីសាស្ត្ររបស់រដ្ឋាភិបាលទាំងមូលក្នុងការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ ។ ក្រសួងដែលទទួលខុសត្រូវ និងអាជ្ញាធរមានសមត្ថកិច្ចដែលទទួលខុសត្រូវលើការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ គួរតែត្រូវបានកំណត់ និងកំណត់មុខងារ និងការទទួលខុសត្រូវ។ យន្តការអន្តរក្រសួងសម្រាប់ការសម្របសម្រួល និងការបញ្ជូនបន្ត រវាងក្រសួងនិងក្រសួង និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគួរតែត្រូវបានបង្កើតឡើងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដែលមានក្រសួង ឬទីភ្នាក់ងារដឹកនាំជា ជនបង្គោល ហើយរួមមានក្រសួងពាក់ព័ន្ធសម្រាប់កិច្ចការនារី ការការពារកុមារ និងសេវាសង្គម។

39. រដ្ឋសមាជិកអាស៊ាន នីមួយៗត្រូវបានលើកទឹកចិត្តឱ្យលើកកម្ពស់វិធីសាស្ត្រសង្គមទាំងមូលក្នុងការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ។ ក្រសួងដែលទទួលខុសត្រូវ និងអាជ្ញាធរមានសមត្ថកិច្ចត្រូវបានលើកទឹកចិត្តឱ្យបង្កើតយន្តការដើម្បីសម្របសម្រួលពហុភាគីដែលមានតំណាងរដ្ឋាភិបាល ដៃគូសង្គម/ត្រីភាគី និងភាគីពាក់ព័ន្ធដែលសមស្រប។

*VI.1.4ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធប្រមូលទិន្នន័យ និងប្រព័ន្ធវិភាគគ្រប់ជ្រុងជ្រោយ ដើម្បីយល់កាន់តែច្បាស់ និងឆ្លើយតបទៅនឹងតម្រូវការរបស់ពលករទេសន្តរប្រវេសន៍នេសាទ*

40. ដោយស្របតាមច្បាប់ជាតិ រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យធ្វើកិច្ចសហប្រតិបត្តិការលើការប្រមូល ការចែករំលែក និងការវិភាគទិន្នន័យ ប៉ុន្តែមិនកំណត់ចំពោះករណីបណ្តឹង ការគ្រប់គ្រងករណី ការជ្រើសរើស ការជួលឱ្យធ្វើការងារ និងការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍នេសាទក្នុង និងក្រៅតំបន់អាស៊ាន និងចែករំលែកការអនុវត្តដ៏ល្អបំផុត និងបទពិសោធន៍ ដែលបានរៀននៅក្នុងដំណើរការធ្វើទេសន្តរប្រវេសន៍របស់ពលករទេសន្តរប្រវេសន៍នេសាទ ដោយគិតគូរពីឯកជនភាពរបស់ពលករទេសន្តរប្រវេសន៍នេសាទ និងសមាជិកគ្រួសាររបស់ពួកគេ ការរក្សាការសម្ងាត់នៃទិន្នន័យដែលប្រមូលបានដើម្បីគោរពគោលការណ៍មិនបង្កគ្រោះថ្នាក់ និងគោលការណ៍តម្លាភាពដូចបានរៀបរាប់ខាងលើ ជាពិសេសពលករទេសន្តរប្រវេសន៍នេសាទដែលមិនមានឯកសារគ្រប់គ្រាន់។

41. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យពង្រឹងសមត្ថភាព និងរចនាសម្ព័ន្ធជាតិ ព្រមទាំងកិច្ចសហប្រតិបត្តិការពហុភាគីដែលពាក់ព័ន្ធសម្រាប់ការប្រមូល និងវិភាគទិន្នន័យ ការស្រាវជ្រាវ ច្បាប់ គោលនយោបាយ និងការអនុវត្តលើការការពារ និងការដាក់ឱ្យធ្វើការសម្រាប់ពលករទេសន្តរប្រវេសន៍នេសាទ ស្របតាមច្បាប់ជាតិ បទប្បញ្ញត្តិ និងគោលនយោបាយរបស់រដ្ឋសមាជិកអាស៊ាន ។

42. ទិន្នន័យស្តីពីពលករទេសន្តរប្រវេសន៍នេសាទ គួរតែត្រូវបានប្រមូលដោយមានការយល់ព្រមពីពួកគេ ដោយការពារ និងរក្សាទុកក្នុងលក្ខណៈដែលគោរពសិទ្ធិទទួលបានឯកជនភាព ការរក្សាការសម្ងាត់ គោលការណ៍មិនបង្កគ្រោះថ្នាក់ និងភាពស្មោះត្រង់របស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ជាពិសេសអ្នកក្នុងស្ថានភាពមិនទៀងទាត់។ ទិន្នន័យស្តីពីពលករទេសន្តរប្រវេសន៍នេសាទ និងគ្រួសាររបស់ពួកគេគួរតែត្រូវបានបែងចែកជាអប្បបរមាតាមអាយុ និងភេទក្នុងករណីដែលមាន និងអាចចូលប្រើប្រាស់បានសម្រាប់ពលករទេសន្តរប្រវេសន៍នេសាទ និងគ្រួសាររបស់ពួកគេ។.

43. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យពិចារណាបន្ថែមលើមូលដ្ឋានទិន្នន័យបរិស័យនូវការស្ទង់មតិគំរូឯកទេសតាមកាលកំណត់ដែលនឹងបង្កើតព័ត៌មានគុណវិស័យដែលមានប្រយោជន៍លើកម្រងព័ត៌មាន ជំនាញ និងសមត្ថភាព បទពិសោធ និងទស្សនៈរបស់ពលករទេសន្តរប្រវេសន៍នេសាទ សម្រាប់ការកំណត់គោលដៅសេវាកម្ម និងការគាំទ្រ ក៏ដូចជាការតាមដានផលប៉ះពាល់របស់ពួកគេ។

44. ទីភ្នាក់ងារជ្រើសរើសគួរតែត្រូវបានលើកទឹកចិត្តឱ្យរក្សាទុកឱ្យបានទៀងទាត់នូវកំណត់ត្រារបស់ពលករទេសន្តរប្រវេសន៍នេសាទ ដែលពួកគេបានជ្រើសរើស និងដាក់ឱ្យធ្វើការងារនៅក្រៅប្រទេស និងតាមដាន និងរាយការណ៍អំពីការធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាព និងថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍ទាំងនោះទៅកាន់សេវាកុងស៊ុលនៃប្រទេសបញ្ជូន និងទៅរដ្ឋាភិបាលនៃប្រទេសបញ្ជូន។ ក្រោយមកទៀតគួរតែពិនិត្យឡើងវិញយ៉ាងទៀងទាត់នូវការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើស និងផ្តល់យោបល់ដល់ភ្នាក់ងារជ្រើសរើសដោយផ្អែកលើវិធានការដាក់ស្តែង និងអាចធ្វើទៅបាន និងតាមគោលនយោបាយរបស់ប្រទេសបញ្ជូននីមួយៗ។

*VI.1.5. ពង្រឹងការរាយការណ៍ ការត្រួតពិនិត្យ និងការអនុវត្ត រួមទាំងតាមរយៈការអធិការកិច្ចការងារ និងវិធានការរដ្ឋកំពង់ផែ*

45. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យបង្កើត ឬពង្រឹងប្រព័ន្ធដែលមានប្រសិទ្ធភាព ( ឧទាហរណ៍ ប្រព័ន្ធផ្សេងៗ រួមទាំងប្រព័ន្ធត្រួតពិនិត្យដែលនាំឱ្យមានការអនុវត្តសិទ្ធិការងារសម្រាប់ការសម្រេចបាននូវគោលការណ៍ជាមូលដ្ឋាននៃសិទ្ធិនៅកន្លែងធ្វើការ ) សម្រាប់ការត្រួតពិនិត្យការរស់នៅ លក្ខខណ្ឌការងារ និង សុវត្ថិភាព និងសុខភាព នៅលើនាវានេសាទ។ ក្នុងការបង្កើតប្រព័ន្ធនេះ រដ្ឋគួរតែផ្តល់ភារកិច្ចដល់អាជ្ញាធរមានសមត្ថកិច្ចដែលមានអាណត្តិច្បាស់លាស់ដើម្បីត្រួតពិនិត្យ និងពង្រឹងបទដ្ឋានការងារ សុវត្ថិភាព និងសុខភាពសម្រាប់ពលករទេសន្តរប្រវេសន៍នេសាទ និងចេញឯកសារ។ គ្រប់ករណីទាំងអស់រដ្ឋសមាជិកអាស៊ាន នឹងនៅតែទទួលខុសត្រូវទាំងស្រុងចំពោះការធ្វើអធិការកិច្ច និងការចេញឯកសារពាក់ព័ន្ធទាក់ទងនឹងការរស់នៅ លក្ខខណ្ឌការងារ សុវត្ថិភាព និងសុខភាព របស់ពលករទេសន្តរប្រវេសន៍នេសាទ នៅលើនាវានេសាទដែលដាក់ទង់ជាតិរបស់ខ្លួន។

46. មុខងារនៃអធិការកិច្ចការងារនឹងធានាដល់ការអនុវត្តបទប្បញ្ញត្តិច្បាប់ទាក់ទងនឹងលក្ខខណ្ឌការងារក្នុងការនេសាទ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ ដូចជាសុវត្ថិភាព និងសុខភាពការងារ ការទប់ស្កាត់ និងលុបបំបាត់អំពើហិង្សា និងការបៀតបៀននៅកន្លែងធ្វើការ រួមទាំងការបៀតបៀនផ្លូវភេទ ប្រាក់ឈ្នួល ម៉ោងធ្វើការ និងម៉ោងបន្ថែម ថ្ងៃឈប់សម្រាក និងពេលសម្រាករួមទាំងការសុំច្បាប់ឈឺ និងសុំច្បាប់សម្រាក គោល

ការណ៍ជាមូលដ្ឋាន និងសិទ្ធិនៅកន្លែងធ្វើការ ទំនាក់ទំនងការងារ ការចុះឈ្មោះ និងប្រាក់វិភាគទានសន្តិសុខសង្គម ការការពារស្ត្រី កុមារ និងជនវ័យក្មេង។

47. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យវិនិយោគលើការពង្រឹងសមត្ថភាពស្ថាប័ននៃប្រព័ន្ធអធិការកិច្ចការងារ ជាពិសេសធានាបាននូវចំនួនអ្នកធ្វើអធិការកិច្ចឱ្យបានគ្រប់គ្រាន់ ធានាថាអ្នកអធិការកិច្ចការងារត្រូវបានបណ្តុះបណ្តាលត្រឹមត្រូវ និងបែងចែកធនធានគ្រប់គ្រាន់ដើម្បីបំពេញកាតព្វកិច្ចអធិការកិច្ច។

48. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យបង្កើតយន្តការផ្លូវការនៅថ្នាក់ជាតិដែលពាក់ព័ន្ធ ដែលអាចធ្វើការចែករំលែកព័ត៌មាន ការសិក្សា និងការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាពនៅទូទាំងស្ថាប័ន ដូចជាក្រសួង អាជ្ញាធរផ្សេងទៀត ដៃគូសង្គម/ត្រីភាគី និងវិទ្យាស្ថានស្រាវជ្រាវ ក៏ដូចជាភាគីពាក់ព័ន្ធដែលចូលរួមក្នុងការដោះស្រាយការនេសាទខុសច្បាប់ មិនបានរាយការណ៍ និងមិនមានការត្រួតពិនិត្យ ដើម្បីបើកការចែករំលែកទិន្នន័យដែលត្រូវការសម្រាប់ការកំណត់អត្តសញ្ញាណសកម្មភាពដែលមានហានិភ័យខ្ពស់។

49. ក្រុមអធិការកិច្ចការងារ តាមរយៈការសហការជាមួយស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ តាមភាពសមស្រប គួរតែប្រើវិធានការផ្សេងៗដើម្បីធានាបានថាមានការឆ្លើយតបសមាមាត្រទៅនឹងការរំលោភច្បាប់ និងតាមការអនុវត្តជាក់ស្តែង ដើម្បីជូនដំណឹងអំពីភាពខ្វះចន្លោះ ឬការរំលោកបំពាននានាដល់អាជ្ញាធរមានសមត្ថកិច្ច ដែលមិនបានបញ្ជាក់តាមច្បាប់ដែលមានស្រាប់ ដើម្បីផ្តល់ដំបូន្មាន និងព័ត៌មាន ប្រើប្រាស់ការចុះសួរសុខទុក្ខដោយមិនប្រាប់ទុកមុន និងដើម្បីសម្របសម្រួលប្រកបដោយប្រសិទ្ធភាពជាមួយនិយោជក និងពលករ និងអ្នកតំណាងរបស់ពួកគេ ដើម្បីប្រាកដថាច្បាប់ត្រូវបានអនុវត្ត។

50. វិសាលភាពនៃទោសទណ្ឌដែលអាចកើតមានចំពោះអ្នកធ្វើអធិការកិច្ចការងារគួរត្រូវបានកំណត់ដោយច្បាប់ និងគួរតែមានលក្ខណៈទូលំទូលាយគ្រប់គ្រាន់ និងបែងចែកភាពខុសប្លែកគ្នា ដើម្បីអាចចាត់ទុកការបំពានដែលមិនមានលក្ខណៈធ្ងន់ធ្ងរស្មើគ្នា តាមលក្ខណៈដែលឆ្លុះបញ្ចាំងពីភាពខុសគ្នានេះ និងអាចបង្កើតជារបាំងរាំងការបំពានជាក់ស្តែងផងដែរ។

51. អធិការដ្ឋានការងារត្រូវបានលើកទឹកចិត្តឱ្យសហការជាមួយអង្គការរបស់កម្មករនិយោជិត និងរបស់និយោជកក្នុងការបង្កើត អនុម័ត និងពិនិត្យគោលនយោបាយអធិការកិច្ច យុទ្ធសាស្ត្រ ឬកម្មវិធី និងផែនការតាមការសមស្រប។ កិច្ចសហការនេះអាចមានទម្រង់ផ្សេងៗគ្នា ដូចជាតាមរយៈស្ថាប័នពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិ កិច្ចព្រមព្រៀងស្តីពីការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ គណៈកម្មាធិការចម្រុះ ការពិគ្រោះយោបល់ និងការរៀបចំយុទ្ធនាការផ្សព្វផ្សាយផ្សេងៗ។

52. **នៅពេលដែលសមស្រប** រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យបង្កើតបទដ្ឋានច្បាស់លាស់ និងការអនុវត្តអធិការកិច្ចការងារដើម្បីធានាបាននូវកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរវាងសេវាអធិការកិច្ចការងារនៅក្នុងប្រទេសបញ្ជូន និងប្រទេសទទួល និងអាជ្ញាធរដែលអនុវត្តនៅរដ្ឋដែលជាក់ទង់ជាតិ រដ្ឋដែលមានកំពង់ផែ និងដែនសមត្ថកិច្ចតាមឆ្នេរសមុទ្រ។ ដើម្បីធានាថាការសម្របសម្រួល និងកិច្ចសហការនេះមានអត្ថន័យ ទើបគួរត្រូវរៀបចំការងារនេះជាអចិន្ត្រៃយ៍ និងទៀងទាត់ និងអនុម័តទម្រង់បែបបទតាមស្ថាប័ន ដូចជាពិធីសារ និងអនុស្សរណៈនៃការយោគយល់គ្នារវាងស្ថាប័នរបស់រដ្ឋាភិបាលដែលគួរផ្សព្វផ្សាយជាសាធារណៈ។

53. **នៅពេលដែលសមស្រប** រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យធានាថានីតិវិធីបណ្តឹងអាចទទួលនិងប្រើបានដោយពលករនេសាទ សហជីព ស្ថាប័នជំនាញ និងភាគីពាក់ព័ន្ធ ឬជាទូទៅ បុគ្គលណាម្នាក់ ដែលមានចំណាប់អារម្មណ៍លើសិទ្ធិការងារ សុខភាព និងសុវត្ថិភាពរបស់ពលករទេសន្តរប្រវេសន៍នេសាទ នៅលើនាវា។

54. ម្ចាស់នាវានេសាទគួរតែត្រូវបានអនុញ្ញាតឱ្យដំឡើងប្រព័ន្ធត្រួតពិនិត្យរួមមានជាអាទិ៍ ប្រព័ន្ធកំណត់ទីតាំងសកល (GPS) ប្រព័ន្ធត្រួតពិនិត្យនាវា (VMS) កាមេរ៉ាសុវត្ថិភាព (CCTV) ឬប្រព័ន្ធផ្សេងទៀត ដោយអនុលោមតាមបទប្បញ្ញត្តិការពារទិន្នន័យ និងសិទ្ធិឯកជនភាពក្នុងគោលបំណងត្រួតពិនិត្យ និងកត់ត្រាស្ថានភាពការងារ និងការរស់នៅ។

55. នាវានេសាទទាំងអស់ត្រូវតែចុះបញ្ជីជាមួយអាជ្ញាធរជាតិ និង/ឬអង្គការអន្តរជាតិ ដូចជាអង្គការដែនសមុទ្រអន្តរជាតិ (IMO) និងអង្គការគ្រប់គ្រងជលផលក្នុងតំបន់ (RFMO) ស្របតាមបទប្បញ្ញត្តិជាតិ និងអន្តរជាតិ។

## VI.2. ការជ្រើសរើស និងការដាក់ឱ្យធ្វើការដោយយុត្តិធម៌ និងមានក្រមសីលធម៌

56. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យពង្រឹងច្បាប់ និងបទប្បញ្ញត្តិជាតិរបស់ខ្លួនដើម្បីធានាថាការជ្រើសរើសប្រព្រឹត្តទៅតាមរបៀបដែលគោរព ការពារ និងបំពេញតាមសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិដែលពាក់ព័ន្ធ រួមទាំងសិទ្ធិដែលបានបង្ហាញនៅក្នុងអនុសញ្ញាជាមូលដ្ឋានរបស់អង្គការអន្តរជាតិខាងការងារ។

57. ច្បាប់ និងគោលនយោបាយស្តីពីការជ្រើសរើសគួរតែអនុវត្តចំពោះពលករទេសន្តរប្រវេសន៍នេសាទដោយគ្មានការរើសអើង។

58. បទប្បញ្ញត្តិនៃសកម្មភាពជ្រើសរើសបុគ្គលិកគួរតែមានភាពច្បាស់លាស់ មានតម្លាភាព និងត្រូវបានដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព។

59. ច្បាប់គួរតែអនុវត្តឆ្ពោះទៅរកការលុបបំបាត់ការគិតថ្លៃសេវាសម្រាប់ការជ្រើសរើសបុគ្គលិក និងការចំណាយពាក់ព័ន្ធទៅនឹងពលករទេសន្តរប្រវេសន៍នេសាទ និងធានាថា "គោលការណ៍និយោជកបង់ប្រាក់" ត្រូវបានអនុវត្ត។

60. រដ្ឋសមាជិកអាស៊ាន គួរតែគិតគូរអំពីវិធីសាស្ត្រដែលធានាបាននូវភាពរហ័ស និងងាយស្រួលក្នុងការជ្រើសរើស និងការដាក់ឱ្យពលករទេសន្តរប្រវេសន៍នេសាទធ្វើការ រួមទាំងការបង្កើតវិធីសាស្ត្រលឿនរហ័ស ឬច្រកចេញចូលតែមួយ ដោយមិនកាត់បន្ថយសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍នេសាទ។

61. បើអាចធ្វើទៅបាន គួរតែផ្តល់ជូនអ្នកដែលមានបំណងទៅធ្វើជាពលករទេសន្តរប្រវេសន៍នេសាទទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ នូវព័ត៌មានត្រឹមត្រូវ និងមានបច្ចុប្បន្នភាព ដើម្បីឱ្យពួកគេអាចធ្វើការសម្រេចចិត្តដោយមានព័ត៌មានច្បាស់លាស់អំពីការធ្វើទេសន្តរប្រវេសន៍ និងការសម្រេចចិត្តទៅធ្វើការងារជាសមូលហភាព។ ព័ត៌មានបែបនេះគួរតែរួមបញ្ចូលការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព សិទ្ធិការងារ និងការការពារសន្តិសុខសង្គម សុវត្ថិភាព និងសុខភាពការងារ ការចំណាយលើការធ្វើទេសន្តរប្រវេសន៍ អត្ថប្រយោជន៍ដែលអាចកើតមាន និងហានិភ័យដែលពាក់ព័ន្ធ ការទទួលបានជំនួយ និងព័ត៌មានផ្សេងទៀត។

62. ប្រទេសបញ្ជូនត្រូវបានលើកទឹកចិត្តឱ្យបង្កើតការបណ្តុះបណ្តាលជាកាតព្វកិច្ច ដោយមិនគិតថ្លៃ មានបទដ្ឋាន និងទទួលស្គាល់ការបណ្តុះបណ្តាលមុនចេញដំណើរសម្រាប់ពលករទេសន្តរប្រវេសន៍នេសាទ ដែលរួមមាន(ប៉ុន្តែមិនកំណត់) ព័ត៌មានអំពីច្បាប់ និងបទប្បញ្ញត្តិ – រួមទាំងលក្ខខណ្ឌការងារ ប្រាក់ឈ្នួល សុវត្ថិភាព និងសុខភាពការងារ ការសុំច្បាប់ឈប់សម្រាកឈឺ ម៉ោងសម្រាក ព័ត៌មានស្តីពីសេវាកម្ម យន្តការបណ្តឹង និងការទទួលបានយុត្តិធម៌ (ជាពិសេស របៀបចូលប្រើយន្តការទាំងនេះ នៅពេលនៅលើនាវានេសាទ) លក្ខខណ្ឌការងារ និងជីវភាពទូទៅ ទំនៀមទំលាប់ និងប្រពៃណីនៃយុត្តាធិការរបស់រដ្ឋនានាដែលពលករទេសន្តរប្រវេសន៍នេសាទអាចធ្វើការបាន។ ព័ត៌មានមុនពេលចេញដំណើរគួរតែរៀបរាប់អំពីវិស័យ និងគោលដៅជាក់លាក់ និងរួមបញ្ចូលសមាជិកគ្រួសារ ជាពិសេសទាក់ទងនឹងការពឹងទុកជុំវិញការទំនាក់ទំនង និងព័ត៌មានអំពីយន្តការបណ្តឹង។

63. ក្នុងករណីដែលអាចធ្វើទៅបាន គួររៀបចំទាំងការតម្រង់ទិសមុនចេញដំណើរ និងមុនធ្វើការងារ។ ការតម្រង់ទិសមុនពេលចេញដំណើរគួរតែរួមបញ្ចូលការសង្ខេបអំពីលក្ខខណ្ឌការងារ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម រួមទាំងព័ត៌មានស្តីពីការផ្ទេរប្រាក់ និងផែនការសន្សំប្រាក់ បញ្ហាប្រឈម ឱកាសនៅក្នុងការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មដោយថាហេតុ និងប្រភពព័ត៌មានពាក់ព័ន្ធ ព្រមទាំងផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានពីការបំបែកគ្រួសារមកលើសុខុមាលភាពគ្រួសារ និងការអភិវឌ្ឍរបស់កុមារ។ ការណែនាំតម្រង់ទិសមុនធ្វើការងារគួរតែរួមបញ្ចូលព័ត៌មានអំពីលក្ខខណ្ឌការងារដែលរំពឹងទុក និងហានិភ័យ (ឧទាហរណ៍ ហានិភ័យនៅកន្លែងធ្វើការ ហានិភ័យសង្គម) ឧបសគ្គភាសា និងវប្បធម៌ដែលរំពឹងទុក ពាក្យបណ្តឹង និងយន្តការយុត្តិធម៌ដែលមាន។ ពលករទេសន្តរប្រវេសន៍នេសាទក៏អាចត្រូវបានលើកទឹកចិត្តផងដែរ - ដោយមានការគាំទ្រដ៏សមស្រប - ដើម្បីរៀបចំផែនការសមាហរណកម្មសម្រាប់ការត្រឡប់មកប្រទេសវិញដោយថាហេតុរបស់ពួកគេក្នុងអំឡុងពេលណែនាំតម្រង់ទិសនេះ។

64. ប្រទេសបញ្ជូន និងប្រទេសទទួលត្រូវបានលើកទឹកចិត្តឱ្យសម្របសម្រួលដើម្បីធានាថាពលករទេសន្តរប្រវេសន៍នេសាទមិនត្រូវបានដាក់នៅលើនាវានេសាទដោយគ្មានវិញ្ញាបនបត្រវេជ្ជសាស្ត្រត្រឹមត្រូវ ដែលបញ្ជាក់ពីកាយសម្បទាដើម្បីបំពេញភារកិច្ចរបស់ពួកគេនោះទេ។ ប្រទេសបញ្ជូន និងប្រទេសទទួលត្រូវអនុម័តច្បាប់ បទប្បញ្ញត្តិ និងវិធានការផ្សេងទៀតដែលផ្តល់សម្រាប់លក្ខណៈពិនិត្យសុខភាព ទម្រង់ និងខ្លឹមសារនៃវិញ្ញាបនបត្រវេជ្ជសាស្ត្រ ភាពញឹកញាប់នៃការពិនិត្យ និងរយៈពេលសុពលភាពរបស់វិញ្ញាបនបត្រ និងយល់ព្រមលើភាពត្រូវគ្នា ដើម្បីជៀសវាងហានិភ័យដែលពលករទេសន្តរប្រវេសន៍នេសាទត្រូវចូលរួមក្នុងការវាយតម្លៃផ្នែកវេជ្ជសាស្ត្រជាច្រើនដង។

65. ប្រទេសទទួលនឹងធានាថាពលករទេសន្តរប្រវេសន៍នេសាទមានសិទ្ធិទទួលបានព័ត៌មានក្រោយការមកដល់ ជាពិសេសលើសិទ្ធិ និងទំនួលខុសត្រូវរបស់ពួកគេ វិធានការសុវត្ថិភាព និងសុខភាពការងារ និងមធ្យោបាយសម្រាប់ជំនួយ ប្រសិនបើពួកគេត្រូវការរាយការណ៍ពីកង្វល់ ឬស្វែងរកជំនួយ។

66. តាមរយៈការទទួលស្គាល់វិធីជាច្រើនដែលពលករទេសន្តរប្រវេសន៍នេសាទអាចដឹងថាពួកគេស្ថិតក្នុងស្ថានភាពផ្លូវច្បាប់មិនទៀងទាត់ រដ្ឋសមាជិកអាស៊ាន គួរតែធានាថាពលករទេសន្តរប្រវេសន៍នេសាទមានឯកសារអន្តោប្រវេសន៍ដែលចាំបាច់ដើម្បីផ្តល់ឱ្យពួកគេនូវការការពារឱ្យបានគ្រប់គ្រាន់។

VI.3. សិទ្ធិការងារ

67. រដ្ឋសមាជិកអាស៊ាន ប្រកាន់ខ្ជាប់សិទ្ធិជាមូលដ្ឋាននៅកន្លែងការងាររបស់ពលករទេសន្តរប្រវេសន៍នេសាទ។ ជាពិសេសការធានាថាពលករទេសន្តរប្រវេសន៍នេសាទមានសិទ្ធិកាន់លិខិតឆ្លងដែនផ្ទាល់ខ្លួន និងឯកសារការងារដែលចេញដោយរដ្ឋាភិបាល និងឯកសារផ្ទាល់ខ្លួនដែលស្ថិតនៅក្រោមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយរបស់ប្រទេសទទួល ហើយពួកគេមានសិទ្ធិទទួលបានសិទ្ធិស្មើគ្នា។

68. តាមរយៈការទទួលស្គាល់ហានិភ័យដែលប្រឈមមុខដោយពលករទេសន្តរប្រវេសន៍នេសាទ រដ្ឋសមាជិកអាស៊ាន ត្រូវធានាថាម៉ោងធ្វើការ និងម៉ោងសម្រាកស្របតាមបទដ្ឋានអន្តរជាតិ។

69. រដ្ឋសមាជិកអាស៊ាន គួរតែធានាថាពលករទេសន្តរប្រវេសន៍នេសាទទទួលបានការទូទាត់ប្រាក់ប្រចាំខែ ឬជាទៀងទាត់ រួមទាំងបញ្ជីប្រាក់បៀវត្សរ៍ដែលអាចយល់បានច្បាស់ ឬឯកសារពាក់ព័ន្ធដូចជារបាយការណ៍ធនាគារ ហើយពលករទេសន្តរប្រវេសន៍នេសាទទាំងអស់ដែលធ្វើការលើនាវានេសាទទទួលបានមធ្យោបាយក្នុងការផ្ទេរប្រាក់ទាំងអស់ ឬផ្នែកខ្លះពីការទូទាត់របស់ពួកគេ រួមទាំងប្រាក់ទូទាត់មុនជូនដល់គ្រួសាររបស់ពួកគេ។

70. រដ្ឋសមាជិកអាស៊ាន គួរតែអនុញ្ញាតឱ្យពលករទេសន្តរប្រវេសន៍នេសាទផ្លាស់ប្តូរនិយោជកស្របតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយរបស់ប្រទេសបញ្ជូន និងប្រទេសទទួល។

71. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យលុបបំបាត់ពលកម្មដោយបង្ខំ ការរំលោភសិទ្ធិមនុស្ស និងការរំលោភលើការងាររួមទាំងរត់ពន្ធមនុស្ស និងការជួញដូរមនុស្ស។ រដ្ឋសមាជិកអាស៊ាន គួរតែប្រកាន់យកគោលការណ៍មិនដាក់ទណ្ឌកម្មចំពោះជនរងគ្រោះក្នុងករណីដែលសមស្រប។

72. រដ្ឋសមាជិកអាស៊ាន គួរតែលុបបំបាត់ពលកម្មកុមារក្នុងចំណោមពលករទេសន្តរប្រវេសន៍នេសាទ រួមទាំងតាមរយៈការពង្រឹងច្បាប់ស្តីពីអាយុអប្បបរមាឱ្យស្របតាមអនុសញ្ញាអាយុអប្បបរមាឆ្នាំ ១៩៧៨ (លេខ១៣៨) និងលិខិតុបករណ៍ដែលពាក់ព័ន្ធផ្សេងទៀត។

73. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យធានាថាពលករទេសន្តរប្រវេសន៍នេសាទមានសិទ្ធិទទួលបានប្រព្រឹត្តកម្មដ៏ត្រឹមត្រូវនៅកន្លែងធ្វើការដោយគ្មានការរើសអើង។ រដ្ឋសមាជិកអាស៊ាន ក៏គួរតែអនុម័តវិធានការដែលតម្រូវឱ្យការស្នាក់នៅលើនាវានេសាទដែលដាក់ទង់ជាតិរបស់ខ្លួន ត្រូវមានទំហំ និងគុណភាពគ្រប់គ្រាន់។ ឧទាហរណ៍ មានចន្លោះខាងលើក្បាលគ្រប់គ្រាន់ មិនមានការបើកទ្វាចូលដោយផ្ទាល់ទៅក្នុងបន្ទប់ពីកន្លែងដាក់ត្រី និងកន្លែងដាក់គ្រឿងម៉ាស៊ីន អ៊ីសូឡង់ វិធានការការពារកន្លែងស្នាក់នៅទប់ស្កាត់រុយ និងសត្វល្អិត ផ្លូវរត់គេចពេលមានអាសន្ន វិធានការដែលកំណត់កម្រិតសំឡេងរំខាន និងរំញ័រខ្លាំង ខ្យល់ចេញចូល កម្តៅគ្រប់គ្រាន់ ភ្លឺគ្រប់គ្រាន់ (មានពន្លឺធម្មជាតិបន្ថែមលើពន្លឺសិប្បនិម្មិត ប្រសិនបើអាចអនុវត្តបាន)។

74. រដ្ឋសមាជិកអាស៊ាន គួរតែធានាសុវត្ថិភាព និងសុខភាពការងារនៅលើនាវា ជាពិសេសតាមរយៈការអនុម័តច្បាប់ និងបទប្បញ្ញត្តិស្តីពីការការពារគ្រោះថ្នាក់ការងារ ជំងឺពីការងារ និងហានិភ័យទាក់ទងនឹងការងារនៅលើនាវា ផ្តល់ការបណ្តុះបណ្តាលដល់ពលករនេសាទ មេបញ្ជានាវា និងម្ចាស់/ប្រតិបត្តិករនាវា បង្កើតយន្តការរាយការណ៍ដើម្បីរាយការណ៍ ស៊ើបអង្កេត និងចាត់វិធានការកែតម្រូវចំពោះគ្រោះថ្នាក់ និងជំងឺនៅពេលជិះលើនាវា ធានាឱ្យនាវាផ្ទុកឧបករណ៍ និងគ្រឿងបរិក្ខារពេទ្យសមស្រប បង្កើតតម្រូវការច្បាស់លាស់សម្រាប់ "អាហារ និងទឹកគ្រប់គ្រាន់" និងនីតិវិធីសម្រាប់ការវាយតម្លៃសុវត្ថិភាពការងារ និងសុខភាពក្នុងអំឡុងពេលអធិការកិច្ចការងារ។ រដ្ឋសមាជិកអាស៊ាន នឹងធានាយ៉ាងច្បាស់ថា មេបញ្ជាការនាវាមានទំនួលខុសត្រូវចំពោះសុវត្ថិភាព និងសុខភាពការងាររបស់ពលករនេសាទដែលនៅលើនាវា ហើយម្ចាស់នាវាមានទំនួលខុសត្រូវរួមក្នុងការធានាថា មេបញ្ជាការនាវាត្រូវបានផ្តល់ធនធាន និងមធ្យោបាយចាំបាច់ដើម្បីអនុវត្តតាមកាតព្វកិច្ចនេះ។

75. កិច្ចព្រមព្រៀងស្តីពីរយៈពេលអប្បបរមាតាមបទដ្ឋាននៃការងាររបស់ពលករនេសាទ (ឬឯកសារដែលសមស្រប) ត្រូវបានបង្កើតឡើង និងផ្តល់ជូនពលករទេសន្តរប្រវេសន៍នេសាទជាភាសាអង់គ្លេស ក៏ដូចជាភាសាដែលពួកគេយល់បានផងដែរ។ កិច្ចព្រមព្រៀងស្តីពីការងាររបស់ពលករនេសាទតាមបទដ្ឋាន (ឬឯកសារដែលសមស្រប) យកចិត្តទុកដាក់ជាពិសេសចំពោះចំណុចដូចខាងក្រោម៖ (ក) ចំនួនប្រាក់ឈ្នួល ឬបរិមាណចំណែកនៃការចាប់ត្រី និងវិធីគណនាប្រាក់ឈ្នួល និងប្រាក់ឈ្នួលអប្បបរមាដែលបានព្រមព្រៀងគ្នា (ខ) លក្ខខណ្ឌបញ្ចប់កិច្ចព្រមព្រៀង និង (គ) ការការពារដែលនឹងធានារ៉ាប់រងលើពលករនេសាទក្នុងករណីមានជំងឺ របួស ឬស្លាប់ (ឃ) ការធានារ៉ាប់រងសុខភាព និងរបបសន្តិសុខសង្គម និងអត្ថប្រយោជន៍ដែលត្រូវផ្តល់ជូនអ្នកនេសាទដោយនិយោជក ម្ចាស់នាវានេសាទ ឬភាគីផ្សេងទៀត ឬភាគីកិច្ចព្រមព្រៀងស្តីពីការងាររបស់ពលករនេសាទតាមដែលអាចអនុវត្តបាន និង (ង) រយៈពេលអប្បបរមានៃការសម្រាក។

76. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យអនុម័តច្បាប់ បទប្បញ្ញត្តិ ឬវិធានការផ្សេងទៀតសម្រាប់នាវានេសាទដែលលើកទង់ជាតិរបស់ខ្លួនទាក់ទងនឹងកន្លែងស្នាក់នៅ អាហារ និងទឹកដែលអាចប្រើប្រាស់បាននៅលើនាវាដោយយោងទៅលើបទដ្ឋានអន្តរជាតិ។

77. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យមើលថែទាំពលករនេសាទដែលរស់នៅក្នុងទឹកដីរបស់ខ្លួនជាធម្មតា និងអ្នកនៅក្នុងបន្ទុករបស់ពួកគេ។ ពួកគេមានសិទ្ធិទទួលបានអត្ថប្រយោជន៍ពីការការពាររបស់របបសន្តិសុខសង្គមក្នុងកម្រិតដែលមានចែងក្នុងច្បាប់ជាតិ។ សមាជិកនីមួយៗត្រូវចាត់វិធានការទៅតាមកាលៈទេសៈជាតិ ដើម្បីសម្រេចបាននូវការការពាររបបសន្តិសុខសង្គមគ្រប់ជ្រុងជ្រោយជាលំដាប់សម្រាប់ពលករនេសាទទាំងអស់ដែលមានទីលំនៅក្នុងទឹកដីរបស់ខ្លួន។

78. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យធ្វើកិច្ចសហប្រតិបត្តិការតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី ឬការរៀបចំផ្សេងទៀតដែលស្របតាមច្បាប់ជាតិ បទប្បញ្ញត្តិ ឬការអនុវត្ត៖ (ក) ដើម្បីទទួលបានការការពាររបបសន្តិសុខសង្គមគ្រប់ជ្រុងជ្រោយជាលំដាប់សម្រាប់ពលករទេសន្តរប្រវេសន៍នេសាទដោយគិតគូរពីគោលការណ៍សមភាពនៃការប្រតិបត្តិដោយមិនគិតពីសញ្ជាតិ និង (ខ) ដើម្បីធានាដល់ការថែរក្សា និងការផ្ទេរសិទ្ធិ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម ដែលទទួលបាន ឬកំពុងស្ថិតក្នុងដំណាក់កាលដែលពលករនេសាទទាំងអស់ទទួលបានដោយមិនគិតពីទីលំនៅ។

79. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យបង្កើតប្រព័ន្ធដើម្បីឱ្យពលករទេសន្តប្រវេសន៍នេសាទអាចទទួលបានការថែទាំខាងវេជ្ជសាស្ត្រដ៏សមស្រប និងអត្ថប្រយោជន៍របស់របបសន្តិសុខសង្គមក្នុងករណីដែលមានរបួសដោយសារគ្រោះថ្នាក់ពីការងារ ឬជំងឺស្របតាមបទដ្ឋានអន្តរជាតិតាមភាពសមស្រប។

80. ស្របតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយជាតិរបស់ រដ្ឋសមាជិកអាស៊ាន ប្រទេសបញ្ជូន និងប្រទេសទទួល ក៏ដូចជារដ្ឋដែលមានឆ្នេរសមុទ្រ រដ្ឋដែលមានកំពង់ផែ និងរដ្ឋដែលដាក់ទង់ជាតិ ខិតខំការពារសិទ្ធិរបស់ពលករទេសន្តប្រវេសន៍នេសាទក្នុងការចូលរួមសហជីពដោយសេរី និងត្រូវបានការពារដោយសហជីពជាមួយកិច្ចព្រមព្រៀងស្តីពីការចរចាជាសមូហភាពដែលមានស្រាប់។

VI.4. សិទ្ធិទទួលបានការប្រាស្រ័យទាក់ទង និងព័ត៌មាន

81. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យធានាថាពលករនេសាទទាំងអស់នៅលើនាវានឹងទទួលបានមធ្យោបាយប្រាស្រ័យទាក់ទងដ៏សមហេតុផលក្នុងកម្រិតដែលអាចអនុវត្តបានក្នុងតម្លៃសមរម្យ និងមិនលើសពីតម្លៃពេញដល់ម្ចាស់នាវានេសាទ។ ប្រសិនបើអាចធ្វើទៅបាន គួរតែមានការចូលប្រើអ៊ីនធឺណិតដោយឥតគិតថ្លៃនៅលើនាវា មធ្យោបាយប្រាស្រ័យទាក់ទងគួរតែគោរពឯកជនភាព និងសុវត្ថិភាពរបស់ពលករទេសន្តប្រវេសន៍នេសាទ។

82. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យធានាឱ្យប្រាកដថាព័ត៌មានទំនាក់ទំនងរបស់ស្ថានទូត អនុព័ន្ធការងារ អ្នកផ្តល់សេវា និងទីជម្រកផ្សេងទៀត រួមទាំងធនធាន និងសេវាសុខភាពផ្លូវកាយ និងផ្លូវចិត្តនៅក្នុងកំពង់ផែ និងរដ្ឋដែលមានឆ្នេរសមុទ្រព្រមទាំងព័ត៌មានស្តីពីប្រព័ន្ធបញ្ជូន និងយន្តការបណ្តឹងដែលអាចរកបាន និងអាចចូលដំណើរការបានសម្រាប់ពលករទេសន្តប្រវេសន៍នេសាទគ្រប់ពេលវេលាក្នុងទម្រង់ និងភាសាដែលពួកគេយល់។

83. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យផ្តល់ និងអនុញ្ញាតឱ្យផ្តល់ជំនួយកុងស៊ុលដល់ពលករទេសន្តប្រវេសន៍នេសាទហើយប្រសិនបើចាំបាច់ ផ្តល់សេវាបកប្រែភាសា និងបកប្រែដោយផ្ទាល់។

84. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងគំនិតផ្តួចផ្តើមពហុភាគីដែលមានគោលបំណងលើកកម្ពស់ការយល់ដឹងរបស់ពលករទេសន្តប្រវេសន៍នេសាទ អំពីពលករ និងសិទ្ធិរបស់ពួកគេ រួមទាំងតាមរយៈការប្រើប្រាស់ធនធានសំឡេង រូបភាព និងបច្ចេកវិទ្យា។

85. ប្រទេសបញ្ជូនត្រូវបានលើកទឹកចិត្តឱ្យធានាថាព័ត៌មានការធ្វើទេសន្តប្រវេសន៍ការងារគឺប្រកបដោយបរិយាបន្នសម្រាប់គ្រួសារពលករទេសន្តប្រវេសន៍នេសាទ រួមទាំងការទទួលបានព័ត៌មានអំពីរបៀបស្វែងរកជំនួយទាក់ទងនឹងពលករទេសន្តប្រវេសន៍នេសាទ ។

86. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យផ្តល់ព័ត៌មាន និងការចូលទៅកាន់បណ្តាញផ្ទេរប្រាក់ រួមជាមួយនឹងកម្មវិធីចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ពលករទេសន្តប្រវេសន៍នេសាទ និងក្រុមគ្រួសាររបស់ពួកគេ។

VI.5. ការអភិវឌ្ឍជំនាញ ការផ្តល់វិញ្ញាបនបត្រ និងការទទួលស្គាល់

87. ប្រសិនបើសមស្រប រដ្ឋសមាជិកអាស៊ានត្រូវបានលើកទឹកចិត្តឱ្យសហការគ្នា រួមមានតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី បង្កើតបទដ្ឋានជំនាញ និងសមត្ថភាពសម្រាប់ពលករទេសន្តប្រវេសន៍នេសាទ។

88. ក្នុងករណីដែលអាចធ្វើបាន ប្រទេសបញ្ជូនគួររៀបចំឱ្យមានកិច្ចព្រមព្រៀងទទួលស្គាល់ និងការផ្តល់វិញ្ញាបនបត្រជំនាញដែលទទួលបាននៅបរទេស និងកិច្ចព្រមព្រៀងទទួលស្គាល់ និងការផ្តល់វិញ្ញាបនបត្រសម្រាប់ការសិក្សាដែលមានពីមុន ដោយប្រើអ្នកផ្តល់សេវាជំនាញសាធារណៈ និងឯកជនដែលមានការទទួលស្គាល់ ដូចជាអង្គការកម្មករនិយោជិត ស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ និងអាស៊ាន។ ការទទួលស្គាល់ការសិក្សាដែលមានពីមុន គឺជាដំណើរការកំណត់អត្តសញ្ញាណ ចងក្រងឯកសារ វាយតម្លៃ និងបញ្ជាក់លទ្ធផលសិក្សាផ្លូវការ ក្រៅផ្លូវការ និងមិនផ្លូវការតាមបទដ្ឋានដែលប្រើក្នុងការអប់រំ និងបណ្តុះបណ្តាលផ្លូវការ។ ដូច្នេះ ការទទួលស្គាល់ការរៀនពីមុនផ្តល់ផ្លូវសម្រាប់ពលករទេសន្តប្រវេសន៍នេសាទដែលធ្វើមាតុភូមិនិវត្តន៍ ដើម្បីទទួលបានការទទួលស្គាល់ជំនាញរបស់ពួកគេដោយមិនចាំបាច់ឆ្លងកាត់កម្មវិធីអប់រំ ឬបណ្តុះបណ្តាលផ្លូវការដែលអាចជួយសម្រួលដល់ការចូលទីផ្សារការងារឡើងវិញ។

ប្រទេសបញ្ជូនអាចសហការជាមួយប្រទេសទទួល ដើម្បីផ្លាស់ប្តូរព័ត៌មានអំពីជំនាញរបស់ពលករទេសន្តរប្រវេសន៍នេសាទ។ កម្មវិធីបណ្តុះបណ្តាលខ្លី ឥតគិតថ្លៃ និង/ឬមានប្រាក់ឧបត្ថម្ភអាចរៀបចំសម្រាប់ពលករដើម្បីត្រៀមសម្រាប់ការវាយតម្លៃជំនាញ ឬដើម្បីបង្កើនជំនាញរបស់ពួកគេ។ ព័ត៌មានអំពីកម្មវិធីបែបនេះត្រូវតែអាចចូលប្រើប្រាស់បានសម្រាប់ពលករដែលធ្វើមាតុភូមិនិវត្តន៍ ។

VI.6. អំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ច

89. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យចាត់វិធានការដ៏សមស្រប និងឆ្លើយតបចំពោះយេនឌ័រ ដើម្បីទប់ស្កាត់ និងដោះស្រាយគ្រប់ទម្រង់នៃអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច ពលកម្មដោយបង្ខំ ការជួញដូរមនុស្ស និងពលកម្មកុមាររបស់ពលករទេសន្តរប្រវេសន៍នេសាទ។

90. រដ្ឋសមាជិកអាស៊ាន នឹងកសាងសមត្ថភាពរបស់ស្ថាប័ន និងតួអង្គពាក់ព័ន្ធក្នុងការកំណត់អត្តសញ្ញាណ និងឆ្លើយតបទៅនឹងអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ច រួមទាំងការបង្កើត និងអនុវត្តប្រព័ន្ធដើម្បីកំណត់ និងផ្តល់ការគាំទ្រដល់ជនរងគ្រោះ/អ្នករស់រានមានជីវិតពីអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច ពលកម្មដោយបង្ខំ ការជួញដូរដោយផ្ទាល់ និងពលកម្មកុមារ និងដើម្បីធានាថាពលករទេសន្តរប្រវេសន៍នេសាទដែលត្រូវបានកំណត់ថាជាជនរងគ្រោះ/អ្នករស់រានមានជីវិតពីការជួញដូរមនុស្សមិនត្រូវបានផ្តន្ទាទោសដោយខុសច្បាប់ លើអំពើដែលបានប្រព្រឹត្តដោយសារការជួញដូរមនុស្សស្របតាមអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។

91. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យសហការគ្នាដើម្បីបើកដំណើរការ/សេវាឆ្លើយតប/សម្របសម្រួលពហុវិន័យ និងសម្របសម្រួលសម្រាប់ការកេងប្រវ័ញ្ច រួមទាំងជនរងគ្រោះ/អ្នករស់រានមានជីវិតពីអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច ការជួញដូរមនុស្ស ពលកម្មដោយបង្ខំ ឬពលកម្មកុមារ រវាងប្រទេសទទួល ប្រទេសបញ្ជូន រដ្ឋដែលលើកទង់ជាតិ រដ្ឋដែលមានកំពង់ផែ និងរដ្ឋដែលមានឆ្នេរសមុទ្រ។ វាអាចរួមមានជាអាទិ៍ ការថែទាំខាងវេជ្ជសាស្ត្រនិងផ្លូវចិត្ត សេវាប្រឹក្សា ជំនួយផ្នែកច្បាប់ សេវាបកប្រែផ្ទាល់មាត់ និងបកប្រែឯកសារ លេខទូរសព្ទទាន់ហេតុការណ៍ កន្លែងស្នាក់នៅ និងជំនួយហិរញ្ញវត្ថុ ជាមួយនឹងផ្លូវបញ្ជូនដ៏មានប្រសិទ្ធភាពរវាងផ្នែកផ្សេងៗរបស់ប្រព័ន្ធ។

92. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យបង្កើតយន្តការការពារដ៏សមរម្យ និងមានប្រសិទ្ធភាពសម្រាប់សាក្សីឃើញអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច ការជួញដូរមនុស្ស ដោយគិតគូរដល់ការការពារទិន្នន័យដែលអាចកំណត់អត្តសញ្ញាណផ្ទាល់ខ្លួន ឯកជនភាព និងការសម្ងាត់ ដើម្បីការពារជនរងគ្រោះ និងសាក្សីពីការប៉ះពាល់នាពេលអនាគត។

93. យោងតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយរបស់ រដ្ឋសមាជិកអាស៊ាន គួរតែមានការបែងចែកផ្នែករដ្ឋបាលរវាងការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការការពារជនរងគ្រោះពីពលកម្មដោយបង្ខំ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការជួញដូរមនុស្ស ដើម្បីអនុញ្ញាតឱ្យពលករទេសន្តរប្រវេសន៍នេសាទទាំងអស់ស្វែងរកជំនួយ និងការការពារជាបន្ទាន់ដោយមិនចាំបាច់ភ័យខ្លាចការប្តឹងពីបទឧក្រិដ្ឋកម្ម ការឃុំខ្លួនដោយបំពាន និងការនិរទេសដោយបង្ខំនៅក្នុងវដ្តនៃការធ្វើទេសន្តរប្រវេសន៍ទាំងមូលទេ។ វិធានការការពារទាំងអស់គួរតែប្រើវិធីសាស្ត្រដែលផ្តោតលើជនរងគ្រោះ និងផ្អែកលើសិទ្ធិស្របតាមគោលការណ៍មិនដាក់ទណ្ឌកម្ម ដោយជនដែលត្រូវបានជួញដូរមិនគួរត្រូវបានចាប់ខ្លួន ចោទប្រកាន់ ការឃុំខ្លួន ការកាត់ទោស ឬមួយត្រូវបានផ្តន្ទាទោស ឬដាក់ទណ្ឌកម្មផ្សេងទៀតដែលជាលទ្ធផលដោយផ្ទាល់ពីការជួញដូរមនុស្ស និងធានាសិទ្ធិជនរងគ្រោះក្នុងការដោះស្រាយ។

VI.7. ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម

94. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យអនុវត្តគោលការណ៍ណែនាំអាស៊ាន ស្តីពីការធ្វើមាតុភូមិនិវត្តន៍ ប្រកបដោយប្រសិទ្ធភាព និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ ទាក់ទងនឹងពលករទេសន្តរប្រវេសន៍នេសាទ។

95. ប្រទេសបញ្ជូនត្រូវបានលើកទឹកចិត្តឱ្យសហការជាមួយប្រទេសទទួល ដើម្បីធានាបាននូវការធ្វើមាតុភូមិនិវត្តន៍ ប្រកបដោយសុវត្ថិភាព ស្ម័គ្រចិត្ត និងសេចក្តីថ្លៃថ្នូររបស់ពលរដ្ឋរបស់ពួកគេដោយមិនគិតពីស្ថានភាពទេសន្តរប្រវេសន៍។ អនុព័ន្ធការងារ និងមន្ត្រីកុងស៊ុលរបស់ប្រទេសទទួល គួរសហការជាមួយនិយោជក និងទីភ្នាក់ងារជ្រើសរើសពលករ និងជួយសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ ប្រកបដោយសុវត្ថិភាព ស្ម័គ្រចិត្ត និងសេចក្តីថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍ ។

96. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យធានាថាពលករនេសាទនៅលើនាវានេសាទដែលលើកទង់ជាតិរបស់ពួកគេ និងដែលចូលកំពង់ផែបរទេសមានសិទ្ធិធ្វើមាតុភូមិនិវត្តន៍ក្នុងករណីដែលកិច្ចព្រមព្រៀងការងាររបស់ពលករនេសាទបានផុតកំណត់ ឬពលករនេសាទមិនអាចអនុវត្តកាតព្វកិច្ចបានទៀតក្រោមកិច្ចព្រមព្រៀងការងារ ឬមិនអាចត្រូវបានរំពឹងថានឹងអនុវត្តកតាព្វកិច្ចបានក្នុងកាលៈទេសៈជាក់លាក់ ឬត្រូវបានបញ្ចប់ដោយហេតុផលត្រឹមត្រូវដោយពលករនេសាទ ម្ចាស់នាវានេសាទ ឬអាជ្ញាធរពាក់ព័ន្ធដោយធានាថាសិទ្ធិ អត្ថប្រយោជន៍ និងសិទ្ធិទទួលបានទាំងអស់ត្រូវបានបំពេញតាមកិច្ចសន្យា។ ចំណុចនេះក៏អនុវត្តបានផងដែរចំពោះពលករនេសាទពីនាវានោះដែលត្រូវបានជញ្ជូនដោយហេតុផលដូចគ្នាទៅកាន់កំពង់ផែដែលនៅជិតបំផុត។

97. ម្ចាស់នាវានេសាទត្រូវទទួលខុសត្រូវលើការចំណាយលើការត្រឡប់មកប្រទេសវិញ លើកលែងតែពលករនេសាទត្រូវបានរកឃើញថាមានកំហុសធ្ងន់ធ្ងរចំពោះកាតព្វកិច្ចនៃកិច្ចព្រមព្រៀងការងាររបស់ខ្លួន ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាតិ។ រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យបង្កើតប្រព័ន្ធដោយសហការជាមួយភាគីដែលពាក់ព័ន្ធដើម្បីរ៉ាប់រងការចំណាយលើការធ្វើមាតុភូមិនិវត្តន៍ក្នុងករណីដែលមិនអាចទទួលបានការចំណាយពីម្ចាស់នាវាមកវិញបាន ដូចជាក្នុងករណីដែលនាវាត្រូវបានបោះបង់ចោល។ ពលករនិយោជិតមិនគួរត្រូវបានផាកពិន័យចំពោះការខកខានរបស់និយោជកក្នុងការទទួលបានការអនុញ្ញាត និងការយល់ព្រមដែលត្រូវការនោះទេ។ ម្ចាស់នាវាគួរមានកាតព្វកិច្ចរ៉ាប់រងថ្លៃធ្វើមាតុភូមិនិវត្តន៍ ឬបញ្ជូនត្រឡប់មកវិញក្នុងករណីពលករនេសាទស្លាប់។

98. ប្រទេសបញ្ជូនត្រូវបានលើកទឹកចិត្តឱ្យបង្កើតកម្មវិធីសមាហរណកម្មគ្រប់ជ្រុងជ្រោយសម្រាប់ពលករទេសន្តរប្រវេសន៍នេសាទ និងក្រុមគ្រួសាររបស់ពួកគេ ដែលធ្វើមាតុភូមិនិវត្តន៍ ក៏ដូចជាកម្មវិធីការងារសម្រាប់ពលករទេសន្តរប្រវេសន៍នេសាទ ដែលធ្វើមាតុភូមិនិវត្តន៍ដោយគិតគូរពីជំនាញដែលទទួលបានពីការធ្វើទេសន្តរប្រវេសន៍។ ប្រទេសបញ្ជូន និងសហគមន៍គួរតែស្វាគមន៍ពលករទេសន្តរប្រវេសន៍ធ្វើមាតុភូមិនិវត្តន៍ ហើយផ្តល់លទ្ធភាពឱ្យពួកគេទទួលបានសេវាពេលមកដល់។ ប្រទេសបញ្ជូននឹងលើកទឹកចិត្តសហគ្រាសឱ្យជ្រើសរើស ពលករទេសន្តរប្រវេសន៍នេសាទធ្វើមាតុភូមិនិវត្តន៍ជាកម្មករនិយោជិតផ្លូវការ។

## VI.8. សិទ្ធិទទួលបានយុត្តិធម៌ និងដំណោះស្រាយ

99. រដ្ឋសមាជិកអាស៊ាន គួរតែផ្តល់ឱ្យពលករទេសន្តរប្រវេសន៍នេសាទ ដែលអាចជាជនរងគ្រោះនៃការរំលោភបំពាន ការកេងប្រវ័ញ្ច អំពើហិង្សា ការជួញដូរ ឬពលកម្មដោយបង្ខំ ជាមួយនឹងសិទ្ធិទទួលបានប្រព័ន្ធច្បាប់ និងតុលាការប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ស្របតាមច្បាប់ បទបញ្ញា និងគោលនយោបាយជាតិ។

100. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យសហការ និងធ្វើការរួមគ្នារវាងប្រទេសទទួល ប្រទេសបញ្ជូន រដ្ឋដែលដាក់ទង់ជាតិ រដ្ឋដែលមានកំពង់ផែ និងរដ្ឋដែលមានឆ្នេរសមុទ្រ ក្នុងការស៊ើបអង្កេត និងកាត់ទោសអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច ពលកម្មដោយបង្ខំ ការជួញដូរមនុស្ស និងពលកម្មកុមាររបស់ពលករទេសន្តរប្រវេសន៍នេសាទ និងក្នុងការផ្តល់សិទ្ធិទទួលបានយុត្តិធម៌ដល់ជនរងគ្រោះ និងអ្នករស់រានមានជីវិតទាំងនោះ។

101. ប្រទេសទទួលនឹងជួយសម្រួលដល់ការអនុវត្តមុខងារកុងស៊ុល ដោយអាជ្ញាធរកុងស៊ុល ឬការទូតរបស់ប្រទេសបញ្ជូន នៅពេលដែលពលករទេសន្តរប្រវេសន៍នេសាទ ត្រូវបានចាប់ខ្លួន ឬជាប់នៅក្នុងពន្ធនាគារ ឬឃុំឃាំង ឬឃុំខ្លួនតាមរបៀបផ្សេងទៀតក្រោមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយរបស់ប្រទេសទទួល។ ក្នុងករណីដែលពលករទេសន្តរប្រវេសន៍នេសាទ ត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ការទទួលបានយុត្តិធម៌ និងសិទ្ធិទទួលបានដំណើរការត្រឹមត្រូវរបស់ពួកគេនឹងត្រូវបានសម្របសម្រួល/គាំទ្រដោយប្រទេសទទួល រដ្ឋដែលដាក់ទង់ជាតិ រដ្ឋដែលមានកំពង់ផែ និងរដ្ឋដែលមានឆ្នេរសមុទ្រ តាមដែលអាចអនុវត្តបាន ស្របតាមច្បាប់ និងគោលនយោបាយរបស់ប្រទេសរៀងៗខ្លួន។

102. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យស្វែងរកច្បាប់ដែលធានាថាទាំងទីភ្នាក់ងារជ្រើសរើស និងម្ចាស់នាវានេសាទអាចទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងការទទួលខុសត្រូវក្នុងករណីដែលកាតព្វកិច្ចតាមកិច្ចសន្យាចំពោះពលករទេសន្តប្រវេសន៍នេសាទ មិនត្រូវបានបំពេញតាម។

### VI.9. ការឆ្លើយតប និងជំនួយគាំទ្រក្នុងស្ថានភាពមានវិបត្តិ

103. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យអនុវត្តគោលការណ៍ណែនាំអាស៊ាន ស្តីពីការការពារពលករទេសន្តប្រវេសន៍ និងសមាជិកគ្រួសារក្នុងស្ថានភាពមានវិបត្តិ ទាក់ទងនឹងពលករទេសន្តប្រវេសន៍នេសាទ ក្នុងស្ថានភាពមានវិបត្តិ។ ជាពិសេស រដ្ឋសមាជិកអាស៊ាន គួរតែធានាថា ជំនួយត្រូវបានផ្តល់ជូនដល់ពលករទេសន្តប្រវេសន៍នេសាទ ដែលជាប់គាំង ឬស្ថិតក្នុងស្ថានភាពវិបត្តិ ដូចជាក្នុងទម្រង់នៃការជួយការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្ម អត្ថប្រយោជន៍ និងការគាំពាររបបសន្តិសុខសង្គម។

### VI.10. កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូក្នុងតំបន់

104. នៅកម្រិតថ្នាក់តំបន់ រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យពង្រឹង ឬពិចារណាលើការបង្កើតយន្តការសម្រាប់រាយការណ៍អំពីស្ថានភាពដែលប្រឈមមុខដោយពលករទេសន្តប្រវេសន៍នេសាទ ដើម្បីជួយសម្រួលដល់ការកំណត់ជាមុននូវបញ្ហាប្រឈមដែលអាចកើតឡើងមកលើសិទ្ធិមនុស្សដើម្បីឱ្យមានអន្តរាគមន៍រហ័ស និងមានប្រសិទ្ធភាព។ រដ្ឋសមាជិកអាស៊ាន គួរតែអនុវត្តវិធានការសកម្មដើម្បីបង្កើនកិច្ចការពារពលករទេសន្តប្រវេសន៍នេសាទ និងពង្រឹងការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់បទដ្ឋានការងារអន្តរជាតិ ដែលបានបង្ហាញនៅក្នុងលិខិតុបករណ៍អាស៊ាន និងលិខិតុបករណ៍អន្តរជាតិសមស្រប។

105. ប្រសិនបើសមស្រប យន្តការអន្តរសេសស្ថេម្ពដើម្បីលើកឡើងអំពីការការពារ និងការដាក់ឱ្យពលករទេសន្តប្រវេសន៍នេសាទ ធ្វើការ គួរតែរួមបញ្ចូលស្ថាប័នពាក់ព័ន្ធអាស៊ាននៅទូទាំងសហគមន៍សន្តិសុខនយោបាយអាស៊ាន (APSC) សហគមន៍វប្បធម៌សង្គមអាស៊ាន (ASCC) និងសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)។

106. ស្ថាប័នអាស៊ាន និងអង្គភាពត្រីភាគីក្នុងតំបន់ ជាពិសេសក្រុមប្រឹក្សាសហជីពអាស៊ាន (ATUC) និងសហភាពនិយោជកអាស៊ាន (AEC) នឹងលើកទឹកចិត្ត និងសម្របសម្រួលកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរបស់ភាគីពាក់ព័ន្ធរដ្ឋសមាជិកអាស៊ានលើមូលដ្ឋានក្នុងតំបន់ រួមទាំងនិយោជក និងតំណាងពលករ សង្គមស៊ីវិល និងអង្គភាពកែច្នៃអាហារសមុទ្រ។

## VII. ការកសាងសមត្ថភាពរបស់ស្ថាប័ន និងដៃគូអនុវត្ត

107. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធក្នុងវិស័យអាស៊ាន និងភាគីពាក់ព័ន្ធថ្នាក់ជាតិ និងតំបន់ ដើម្បីបង្កើតការយល់ដឹងរួមអំពីតួនាទីរៀងៗខ្លួនក្នុងការដាក់ឱ្យធ្វើការ និងការពារពលករទេសន្តប្រវេសន៍នេសាទ និងជំរុញកិច្ចខិតខំប្រឹងប្រែងស្តីពីកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួល។

108. គណៈកម្មការអាស៊ានលើការអនុវត្តសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់ពលករទេសន្តប្រវេសន៍ (ACMW) ត្រូវបានលើកទឹកចិត្តឱ្យជួយសម្រួលដល់ការសម្របសម្រួលទ្វេភាគី ឬពហុភាគីរវាង រដ្ឋសមាជិកអាស៊ាន លើបញ្ហាទាក់ទងនឹងការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តប្រវេសន៍នេសាទ។

109. ការស្នើសុំជំនួយអាចស្វែងរកពីក្រសួងមានសមត្ថកិច្ច និងទីភ្នាក់ងារជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិសម្រាប់កិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាព។

## VIII. ការកៀរគរធនធានសម្រាប់ការអនុវត្តគោលការណ៍ណែនាំ

110. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យធានាថាធនធានមនុស្ស និងហិរញ្ញវត្ថុ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធមានសម្រាប់អនុវត្តគោលនយោបាយ និងកម្មវិធីនានា។

111. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យទាក់ទាញការយកចិត្តទុកដាក់លើកិច្ចខិតខំប្រឹងប្រែងជុំវិញការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទទៅកាន់អង្គភាពក្នុងតំបន់ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ បណ្ដាញអង្គការសហប្រជាជាតិស្តីពីការធ្វើទេសន្តរប្រវេសន៍ និងដៃគូសន្ទនាអាស៊ាន សម្រាប់រាល់ជំនួយដែលពួកគេអាចរៀបចំជាទម្រង់បច្ចេកទេស ឬជំនួយហិរញ្ញវត្ថុ។

112. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យលើកកម្ពស់ភាពជាដៃគូសាធារណៈ និងឯកជនដែលអាចធានាបាននូវការអនុវត្តគោលការណ៍ណែនាំសម្រាប់ការដាក់ឱ្យធ្វើការ និងការពារពលករទេសន្តរប្រវេសន៍នេសាទ ។

IX. ការប្រើប្រាស់គោលការណ៍ណែនាំ

113. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យផ្សព្វផ្សាយគោលការណ៍ណែនាំដល់អ្នកប្រើប្រាស់ ភាគីពាក់ព័ន្ធ និងសាធារណជនទូទៅ។ ក្នុងករណីសមស្រប ការផ្សព្វផ្សាយសេចក្តីណែនាំគួរតែត្រូវបានផ្តល់ជាសាធារណៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ រួមទាំងសេចក្តីប្រកាសព័ត៌មាន ទូរទស្សន៍ វិទ្យុ និងបណ្តាញសង្គម។ រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យបកប្រែគោលការណ៍ណែនាំទៅជាភាសាក្នុងតំបន់សម្រាប់ការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយ។

114. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់គោលការណ៍ណែនាំយ៉ាងទូលំទូលាយក្នុងការកែលម្អគោលនយោបាយ និងកម្មវិធីជាតិរបស់ពួកគេ និងចូលរួមក្នុងកិច្ចសន្ទនាជាមួយបណ្តាប្រទេស និងភាគីពាក់ព័ន្ធដែលពាក់ព័ន្ធនៅខាងក្រៅអាស៊ានស្តីពីការដាក់ឱ្យធ្វើការ និងការពារពលករទេសន្តរប្រវេសន៍នេសាទ។ ក្នុងការប្រើប្រាស់គោលការណ៍ណែនាំ រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យសម្របសម្រួល និងសហការជាមួយភាគីពាក់ព័ន្ធដ៏សមស្របនៅក្នុងប្រទេសបញ្ជូន និងប្រទេសទទួល រដ្ឋដែលមានកំពង់ផែ រដ្ឋដែលមានឆ្នេរសមុទ្រ និងរដ្ឋដែលដាក់ទង់ជាតិ។

115. ការអនុវត្តតាមគោលការណ៍ណែនាំ គួរតែត្រូវបានសម្របសម្រួលជាមួយការអនុវត្តយុទ្ធសាស្ត្រស្តីពីទេសន្តរប្រវេសន៍ និងការផ្តល់ការងារជារួមរបស់ រដ្ឋសមាជិកអាស៊ាន ការប្តេជ្ញាចិត្តក្នុងតំបន់ដែលពាក់ព័ន្ធ រួមទាំងឯកច្ឆន្ទភាពអាស៊ាន និងផែនការសកម្មភាពដែលពាក់ព័ន្ធ និងការប្តេជ្ញាចិត្តអន្តរជាតិពាក់ព័ន្ធដែលត្រូវបានអនុម័តដោយ រដ្ឋសមាជិកអាស៊ាន រួមទាំងកិច្ចព្រមព្រៀងក្រោមរបៀបវារៈឆ្នាំ ២០៣០ របស់អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមទាំងកតិកាសញ្ញាសកលស្តីពីសុវត្ថិភាព រៀបរយ និងការធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់។

X. ការត្រួតពិនិត្យ និងការវាយតម្លៃគោលការណ៍ណែនាំ

116. ការតាមដាន ការត្រួតពិនិត្យតាមកាលកំណត់ និងការវាយតម្លៃស្ថានភាពនៃការអនុវត្តគោលការណ៍ណែនាំជាឯករាជ្យគួរតែមានភាពរឹងមាំដឹកនាំដោយ គណៈកម្មការអាស៊ាន ស្តីពីពលករទេសន្តរប្រវេសន៍ និងអនុវត្តដោយរដ្ឋាភិបាល អង្គភាពតំណាងនិយោជក និយោជិត និងអាចរួមបញ្ចូលភាគីពាក់ព័ន្ធ ផ្សេងទៀតដើម្បីធានាថាការគោរពគោលការណ៍ណែនាំត្រូវបានអនុវត្តក្នុងគោលនយោបាយថ្នាក់ជាតិ និងអាស៊ាន។

117. លេខាធិការដ្ឋានអាស៊ានអាចផ្តល់ការគាំទ្រ និងជំរុញនូវការអំពីដំណើរការតាមដាន និងវាយតម្លៃនេះ។

118. រដ្ឋសមាជិកអាស៊ាន ត្រូវបានលើកទឹកចិត្តឱ្យបង្កើតកម្រងការអនុវត្តប្រកបដោយប្រសិទ្ធភាពដែលបានធ្វើបច្ចុប្បន្នភាពយ៉ាងទៀងទាត់ដើម្បីចែករំលែកក្នុងចំណោមរដ្ឋ និងប្រើប្រាស់ដើម្បីគាំទ្រការតាមដាន និងការវាយតម្លៃ។

ឧបសម្ព័ន្ធ៖ សទ្ទានុក្រមពាក្យគន្លឹះជាមួយនិយមន័យ

| | |
|---|---|
| **វិបត្តិ** | សម្រាប់គោលបំណងនៃគោលការណ៍ណែនាំ និងអនុលោមតាមគោលការណ៍ណែនាំរបស់អាស៊ានស្តីពីការការពារពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសារក្នុងស្ថានភាពវិបត្តិ ពាក្យ "វិបត្តិ" សំដៅដល់ភាពអាសន្នផ្នែកសុខភាពសាធារណៈ គ្រោះមហន្តរាយធម្មជាតិ និងវិបត្តិផ្សេងៗដែលកំណត់ដោយរដ្ឋសមាជិកអាស៊ានដែលមានវិបត្តិបានកើតឡើង។ |
| **កិច្ចព្រមព្រៀងស្តីពីការងាររបស់ពលករនេសាទ** | មានន័យថាកិច្ចសន្យាការងារ ប្រការនៃកិច្ចព្រមព្រៀង ឬការព្រមព្រៀងស្រដៀងគ្នាផ្សេងទៀត ឬកិច្ចសន្យាផ្សេងទៀតដែលគ្រប់គ្រងស្ថានភាពរស់នៅ និងការងាររបស់អ្នកនេសាទនៅលើនាវា។ |
| **ពលករទេសន្តរប្រវេសន៍** | ពលករពលករទេសន្តរប្រវេសន៍ "សំដៅទៅលើបុគ្គលទាំងឡាយ ដែលនឹងត្រូវបានចូលរួម ឬនឹងត្រូវបានជួលឲ្យធ្វើការងារ ត្រូវបានចូលរួម ឬត្រូវបានជួលឲ្យធ្វើការងារ ឬក៏បានកំពុងតែចូលរួម ឬបានកំពុងជួលឲ្យធ្វើការងារ ឬបច្ចុប្បន្នបាននឹងកំពុងចូលរួម ឬបាននឹងកំពុងជួលឲ្យធ្វើការងារនៅក្នុងសកម្មភាពដែលទទួលបាននូវប្រាក់ឈ្នួល នៅក្នុងរដ្ឋ ឬប្រទេសដែលមិនមែនជាប្រទេសកំណើតរបស់គាត់/នាង ។[5]" |
| **ពលករទេសន្តរប្រវេសន៍នេសាទ** | ពលករទេសន្តរប្រវេសន៍នេសាទ សំដៅដល់ពលករទេសន្តរប្រវេសន៍ដែលធ្វើការក្នុងគ្រប់សមត្ថភាព ឬប្រកបមុខរបរលើនាវានេសាទពាណិជ្ជកម្ម ដែលដាក់ទង់ជាតិប្រទេសផ្សេងក្រៅពីជាតិរបស់ខ្លួន។[6] |
| **ប្រទេសទទួល** | ឯកច្ចន្ទភាពអាស៊ានប្រើពាក្យថា "ប្រទេសទទួល" ដើម្បីសំដៅដល់រដ្ឋសមាជិកអាស៊ាន ដែលទទួលយកពលករទេសន្តរប្រវេសន៍។ |
| **ប្រទេសបញ្ជូន** | ឯកច្ចន្ទភាពអាស៊ានប្រើពាក្យថា "ប្រទេសបញ្ជូន" ដើម្បីសំដៅដល់ រដ្ឋសមាជិកអាស៊ាន ដែលពលករទេសន្តរប្រវេសន៍មានសញ្ជាតិរបស់ខ្លួន។ |
| **រដ្ឋដែលនាវាលើកទង់ជាតិ** | រដ្ឋសមាជិកអាស៊ាន ដែលនាវាបានចុះបញ្ជី។ |
| **រដ្ឋនៃឆ្នេរសមុទ្រ** | រដ្ឋសមាជិកអាស៊ាន ដែលមានតំបន់បើកចំហដែនសមុទ្រ និងយុត្តាធិការលើសមុទ្រដែនដីរបស់ខ្លួន។ |
| **រដ្ឋនៃកំពង់ផែ** | រដ្ឋសមាជិកអាស៊ាន ដែលអនុញ្ញាតឱ្យមានការចតនៅកំពង់ផែរបស់ខ្លួន។ |
| **ត្រីភាគី និងដៃគូត្រីភាគី** | ត្រីភាគី ត្រូវបានកំណត់ដោយអង្គការអន្តរជាតិខាងការងារ (ILO) ថាជា "អន្តរកម្មរបស់រដ្ឋាភិបាល និយោជក និងកម្មករនិយោជិត (តាមរយៈតំណាងរបស់ពួកគេ) ក្នុងនាមជាដៃគូស្មើភាពគ្នា និងឯករាជ្យ ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហានៃកង្វល់រួម"។[7] ម្យ៉ាងវិញទៀត ត្រីភាគីសំដៅទៅលើការចូលរួមរបស់អង្គការវិជ្ជាជីវៈរបស់និយោជក និងអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត រួមជាមួយនឹងរដ្ឋាភិបាល ដោយស្មើភាពគ្នាក្នុងការសម្រេចចិត្ត។ ប៉ុន្តែមិនមែនមានន័យថា ទំនួលខុសត្រូវរបស់ភាគីទាំងបីដូចគ្នាដែរ។ ភាគីនីមួយៗមានតួនាទី និងមុខងារច្បាស់លាស់ក្នុងការបំពេញ។[8] |

[5] និយមន័យក្នុងឯកច្ចន្ទភាពអាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករ ទេសន្តរប្រវេសន៍

[6] និយមន័យក្នុងសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការដាក់ឱ្យធ្វើការ និងការការពារពលករទេសន្តរប្រវេសន៍នេសាទ

[7] ILO: "កម្រងវេវចនសព្ទ ILO Thesaurus", https://metadata.ilo.org/thesaurus.html.

[8] ILO៖ ការសន្ទនាសង្គមត្រីភាគីថ្នាក់ជាតិ៖ ការណែនាំរបស់ ILO សម្រាប់ការធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ច អង្គភាពសន្ទនាសង្គម និងត្រីភាគីនាយកដ្ឋានអភិបាលកិច្ច និងត្រីភាគី (ទីក្រុងហ្សឺណែវ ឆ្នាំ២០១៣)។